ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY


## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការធ្វើសវនកម្មក្រុមហ៊ុនឌីឡូយ័ធ៍ លើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារវឌ្ឍនៈ អាស៊ីចំកាត់

# AUDIT OF ADVANCED BANK OF ASIA FINANCIAL STATEMENT BY DELOITTE

ជំនាញ គណនេយ្យ


រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
សាកលវិទ្យាល័យវ៉ាន់ដា
VANDA UNIVERSITY

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការធ្វើសវនកម្មក្រុមហ៊ុនឌីឡូយធ៍ លើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារវឌ្ឍនៈ អាស៊ីចំកាត់

AUDIT OF ADVANCED BANK OF ASIA FINANCIAL STATEMENT BY DELOITTE

គ្រូណែនាំ ៖ ឆួយ រស្មី

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥
PHNOM PENH 2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**

**ប្រធានបទ៖ ការធ្វើសវនកម្មក្រុមហ៊ុនឌីឡូយធ៍លើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

ធួយ ស្មើ

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យ វ៉ាន់ដា អស់រយៈពេល៤ ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាពិសេស ក្រុមរបស់យើងខ្ញុំយល់យ៉ាងច្បាស់ថា ជំនាញគណនេយ្យជាជំនាញមួយ ដែលមានសារៈសំខាន់សម្រាប់ទីផ្សារបច្ចុប្បន្នក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវបានអនុវត្តកិច្ចការគណនេយ្យដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗ ដែលពាក់ព័ន្ធនឹងការងារគណនេយ្យតាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់នៅក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារគណនេយ្យ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**ការធ្វើសវនកម្មក្រុមហ៊ុនឌីឡយ៍ធ៍លើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់**" យកមកធ្វើការសិក្សាស្រាវជ្រាវ ដើម្បីចងក្រងក្នុងគោលបំណង ឱ្យអ្នកសិក្សាស្រាវជ្រាវទាំងអស់ ស្វែងយល់ពីអត្ថន័យកាន់តែស៊ីជម្រៅអំពីការរៀបចំសារណា និងដំណើរនៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះនឹងបានចូលរួមចំណែកនៅក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀត ដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



**ស តារាវត្តី**
B22/2332



**ឈឹម រត្តណា**
B22/145



**លីន ដាឡែន**
B22/1237



**ញាញ់ ពុធថា**
B22/432



**ថុន ស៊ីថូ**
B22/660

# **សេចក្តីថ្លែងអំណរគុណ**

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដាថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញគណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងបានផ្តល់នូវបទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះលោកគ្រូ **ឆូយ រស្មី** ជាគ្រូណែនាំដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្រ្តាចារ្យព្រមទាំងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតដល់ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមយើងខ្ញុំជានិស្សិតបរិញ្ញាបត្រជំនាញគណនេយ្យ នៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២៖

សូមធានាអះអាងថា ខ្លឹមសារនៃសារណាក្រោមប្រធានបទស្តីពី "ការធ្វើសវនកម្មក្រុមហ៊ុនឌីឡូយធ៍លើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់" នេះពិតជាស្នាដៃមួយរបស់ក្រុមខ្ញុំបាទ នាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធទៅនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលដែលទាក់ទងទៅនឹងការស្រាវជ្រាវ ដែលបានលើកឡើងនេះជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ.ពុធ.៨កើត ខែ.កត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

ថ្ងៃទី.២៩. ខែ.តុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**

ស តារាវត្តី

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) គឺជាគ្រឹះស្ថានហិរញ្ញវត្ថុឯកជនឈានមុខមួយរបស់កម្ពុជា ( សហគ្រាសពង្រឹងជំហររបស់ខ្លួនបានយ៉ាងរឹងមាំនៅក្នុងទីផ្សារ និងជាធនាគារមួយក្នុងចំណោមធនាគារ ពាណិជ្ជកម្មកំពូលទាំងបីក្នុងប្រទេស)។ ដោយឆ្លងកាត់ការអភិវឌ្ឍ និងកំណើនក្នុងរយៈពេល ២៥ ឆ្នាំកន្លងមកនេះ ABA បាននៅក្នុងប្រទេសជាមួយសាខាចំនួន ៧៩ ទីតាំង ស្វ័យសេវាជាង ៦០០ ទូទាំងប្រទេស, ធនាគារអនឡាញ និងធនាគារតាមទូរស័ព្ទដៃយ៉ាងទំនើប ABA មានបម្រើសេវាជូនដល់បណ្តាអតិថិជនជាច្រើនដូចជា សហគ្រាសធនតូច និងមធ្យម, អាជីវកម្មខ្នាតតូច, និងរូបវន្តបុគ្គលជាមួយនឹងវិសាលគមន៍ទូលំទូលាយនៃសេវាហិរញ្ញវត្ថុ និងសេវាកម្មឌីជីថលដ៏ទំនើប ។

ឆ្លងតាមការបកស្រាយបានបង្ហាញឱ្យឃើញថា ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការបង្កើតឱ្យមាននូវប្រសិទ្ធភាព សុក្រិតភាព និង ឱ្យកាន់តែមានភាពត្រឹមត្រូវ។ លុបបំបាត់នូវ ការកេងប្រវ័ញ្ច និង បញ្ចៀសនូវរាល់ការភ័ន្តច្រឡំ ដែលកើតឡើងដោយអចេតនារបស់គណនេយ្យករ ក្នុងការគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ។ សវនកម្ម គឺជាសកម្មភាពទទួលបន្ទុកវិភាគ និងវាយតម្លៃដំណើរការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រង និងដំណើរការទិសដៅរបស់ក្រុមហ៊ុន។ ក្នុងនេះផងដែរយើងបានរកឃើញពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ធនាគារ ហើយយើងក៏បានធ្វើការសន្និដ្ឋានព្រមទាំងផ្តល់អនុសាសន៍ ដើម្បីឱ្យធនាគារបានកែប្រែ ដើម្បីភាពរីកចម្រើនបន្តទៀត។ ជាទូទៅការវិភាគលើចំណុចខ្លាំង និង ចំណុចខ្សោយលើការអនុវត្តការងារសវនកម្ម គឺជាការវិភាគដែលពិតជាមានសារៈសំខាន់បំផុតក្នុងការវាយតម្លៃ វាស់វែងពីតម្លៃ និងសកម្មភាពរបស់ធនាគារដើម្បីឱ្យធនាគារមានការរីកចម្រើនទៅមុខដោយជោគជ័យ។ បន្ទាប់ពីបានធ្វើការស្រាវជ្រាវ និងវាយតម្លៃលើរបាយការណ៍ និងការអនុវត្តការងាររបស់ធនាគារកន្លងមកនេះយើងខ្ញុំបានរកឃើញនូវចំណុចខ្លាំង នៅក្នុងរបាយការណ៍សវនកម្មឯករាជ្យ ក្រុមហ៊ុនសវនកម្ម Deloitte បានអះអាងថា របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារបានបង្ហាញនូវភាពត្រឹមត្រូវជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី៣១ ធ្នូ ឆ្នាំ២០២៣ និងថ្ងៃទី៣១ ធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់បំណាច់ការិយបរិច្ឆេទដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ ដែលទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាCIFRSs។ ចំពោះចំណុចខ្សោយវិញគឺ ធនាគារមានការកើនឡើងទៅលើបំណុល និងទឹកប្រាក់នៃសំវិធានធនលើអតិថិជនសង្ស័យ។ ព្រមទាំងមានការថយចុះទៅលើគណនីប្រាក់បញ្ញើ និងមិនមានប្រកាសបែងចែកភាគលាភ។

ដោយយើងឃើញមានចំណុចខ្សោយបានលេចឡើង ក្រុមយើងខ្ញុំក៏បានធ្វើការផ្តល់ជាអនុសាសន៍ខ្លះៗ ដើម្បីឱ្យធនាគារបានកែលម្អ និងឈានទៅរកភាពកាន់តែល្បីល្បាញរីកចម្រើនបន្តទៀត។ ធនាគារគួរតែពង្រឹង សមត្ថភាពរបស់សវនកម្មផ្ទៃក្នុងបន្ថែមទៀត ដើម្បីដើរតួជាផ្នែកមួយដ៏រឹងមាំ និងការពារពីការកេងប្រវ័ញ្ចផ្សេងៗ។ ហើយធនាគារគួរតែរកដំណោះស្រាយ ដើម្បីទប់ទល់នឹងហានិភ័យទៅលើការកើនឡើងទៅលើបំណុល និងទឹកប្រាក់នៃសំវិធានធនលើអតិថិជនសង្ស័យ ព្រមទាំងបង្កើនលើអត្រាការប្រាក់ ដើម្បីទាក់ទាញលើប្រភពប្រាក់បញ្ញើ។ ធនាគារគួរស្វែងរកវិធីសាស្ត្រដែលអាចបង្កើនប្រាក់ចំណូល ដើម្បីអាចប្រកាសបែងចែកភាគលាភរៀងរាល់ឆ្នាំ។

# មាតិកា

ទំព័រ

អារម្ភកថា ........ i

រចនាសម្ព័ន្ធក្រុម ........ ii

សេចក្តីថ្លែងអំណរគុណ ........ iii

អំណះអំណាង ........ iv

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v

មាតិកា ........ vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

១. តើដំណើរការនៃការធ្វើសវនកម្មរបស់ក្រុមហ៊ុន Deloitte មកលើរបាយការណ៍ហិរញ្ញវត្ថុធនាគារវឌ្ឍនៈអាស៊ីចំកាត់អនុវត្តយ៉ាងដូចម្តេច?

២. តើធនាគារវឌ្ឍនៈអាស៊ីចំកាត់ទទួលបានផលប្រយោជន៍អ្វីខ្លះ បន្ទាប់ពីក្រុមហ៊ុន Deloitte បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរួច?

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២

១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

១.៤.១ ទំហំដែនកំណត់នៃការស្រាវជ្រាវ ........ ២

១.៤.២ វិសាលភាពនៃការសិក្សាស្រាវជ្រាវ ........ ៣

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣

១.៥.១ វិធីសាស្ត្រដែលបានយកមកប្រើប្រាស់ក្នុងការសរសេរ ........ ៣

១.៥.២ វិធីសាស្ត្រប្រមូលទិន្នន័យ ........ ៣

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៤

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

## ជំពូកទី២
## ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

២.១ លក្ខណៈទូទៅនៃការធ្វើសវនកម្ម ........ ៦

២.១.១ និយមន័យសវនកម្ម ........ ៦

២.១.២ ប្រវត្តិសវនកម្ម ........ ៧

២.១.៣ ប្រភេទសវនកម្ម ........ ៩

២.២ ដំណើរការនៃការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ ........ ១១

២.២.១ និយមន័យរបាយការណ៍ហិរញ្ញវត្ថុ....................................................................១១
២.២.២ ដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុ ...............................................................១១
២.២.៣ សារៈសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ.............................................................. ១២
២.៣ ផលប្រយោជន៍នៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ............................ ១២
២.៣.១ និយមន័យរបស់ធនាគារ ........................................................................... ១២
២.៣.២ ប្រវត្តិទូទៅរបស់ធនាគារ .......................................................................... ១៣
២.៣.៣ ប្រភេទរបស់ធនាគារ................................................................................ ១៣

# ជំពូកទី៣

# ការធ្វើសវនកម្មក្រុមហ៊ុនឌីឡូយធ៍លើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ វឌ្ឍនៈអាស៊ីចំកាត់

៣.១ ស្ថានភាពទូទៅរបស់ Deloitte .................................................................................. ១៦
៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន Deloitte............................................................................ ១៦
៣.១.២ ចក្ខុវិស័យ និងបេសកកម្ម គុណតម្លៃរបស់ក្រុមហ៊ុន Deloitte............................. ១៦
៣.១.៣ អាស័យដ្ឋានរបស់ក្រុមហ៊ុន Deloitte ............................................................ ១៧
៣.១.៤ រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន Deloitte................................................................១៨
៣.២ ដំណើរការនៃការធ្វើសវនកម្មរបស់ក្រុមហ៊ុន Deloitte មកលើធនាគារវឌ្ឍនៈអាស៊ីចំកាត់ ........១៩
៣.២.១ ផែនការរបស់ក្រុមហ៊ុន Deloitte នៃការធ្វើសវនកម្មមកលើធនាគារវឌ្ឍនៈអាស៊ីចំកាត់...១៩
៣.២.២ ការអនុវត្តផែនការរបស់ក្រុមហ៊ុន Deloitte នៃការធ្វើសវនកម្មមកលើធនាគារវឌ្ឍនៈអាស៊ីចំកាត់ ........................................................................................................................ ១៩
៣.៣ ផលប្រយោជន៍នៃការធ្វើសវនកម្មរបស់ក្រុមហ៊ុន Deloitte ទៅលើរបាយការណ៍ហិរញ្ញវត្ថុដែលធនាគារវឌ្ឍនៈអាស៊ីចំកាត់ទទួលបាន ............................................................................២៤

# ជំពូកទី៤

# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង.................................................................................... ២៥
៤.២ ការវិភាគលើចំណុចខ្សោយ ................................................................................. ២៥

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ...............................................................................................២៧
៥.២ ការផ្តល់អនុសាសន៍ ........................................................................................... ២៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នាពេលបច្ចុប្បន្ននេះ យើងឃើញថានៅតាមបណ្តាប្រទេសលើសកលលោក មានការរីកចម្រើនយ៉ាងខ្លាំងស្ទើរគ្រប់វិស័យ។ ក្នុងនោះក៏រួមមានព្រះរាជាណាចក្រកម្ពុជាយើងផងដែរ ដែលកំពុងបោះជំហានទៅលើការអភិវឌ្ឍសេដ្ឋកិច្ចជាតិរបស់ខ្លួន។ យើងបានកត់សម្គាល់ឃើញផងដែរថា នៅពេលបច្ចុប្បន្ននេះប្រទេសកម្ពុជាមានសន្ទុះនៃការអភិវឌ្ឍប្រទេស និងវិវត្តន៍ខ្លួនយ៉ាងឆាប់រហ័ស ពោលគឺបានធ្វើកំណែទម្រង់លើប្រព័ន្ធគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចរបស់ខ្លួន ដោយដើរតាមប្រព័ន្ធទីផ្សារបើកចំហ។

តាមប្រព័ន្ធគ្រប់គ្រងគោលនយោបាយនេះ គួបផ្សំនឹងធនធានវត្ថុធាតុដើមមានស្រាប់ក្នុងប្រទេស កម្លាំងពលកម្មជាមួយប្រាក់ឈ្នួលសមរម្យ រាជរដ្ឋាភិបាលកម្ពុជាក៏មាននូវការជំរុញ និងលើកទឹកចិត្តអ្នកវិនិយោគថ្នាក់ជាតិ និងអន្តរជាតិដោយមានការអនុគ្រោះពន្ធមួយចំនួនផងដែរ។ ដោយកត្តាទាំងអស់នេះហើយ បានទាក់ទាញអ្នកវិនិយោគថ្នាក់ជាតិ និងអន្តរជាតិ តូចធំជាច្រើនមកធ្វើការវិនិយោគទុននៅក្នុងប្រទេសកម្ពុជាជាបន្តបន្ទាប់។ ជាមួយគ្នានេះដែរ ដោយកំណើនអ្នកវិនិយោគមានការកើនឡើង នាំឱ្យសហគ្រាស ក្រុមហ៊ុន ឬអង្គភាពមានការប្រកួតប្រជែងគ្នាយ៉ាងខ្លាំងនៅក្នុងទីផ្សារសេដ្ឋកិច្ច។ ទន្ទឹមគ្នានេះដែរ ដើម្បីឱ្យការប្រកួតប្រជែងនៅលើទីផ្សារមានតម្លាភាព និងគណនេយ្យភាព ព្រមទាំងឈរលើគោលការណ៍ច្បាប់ ចាំបាច់ត្រូវមានយុទ្ធនាការតាមដាន និងត្រួតពិនិត្យច្បាស់លាស់តាមរយៈការធ្វើសវនកម្ម។ សវនកម្ម គឺជាវិធីសាស្ត្រមួយក្នុងការតាមដានឆែកឆេរ ស៊ើបអង្កេត ពិនិត្យផ្ទៀងផ្ទាត់ និងវាយតម្លៃទៅលើដំណើរការអាជីវកម្មរបស់អង្គភាពមួយ ព្រមទាំងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីជានាសម្រេចបានគោលបំណងរបស់អង្គភាពដែលចង់បាន បន្ទាប់មករៀបចំរបាយការណ៍ហិរញ្ញវត្ថុជូនអ្នកប្រើប្រាស់ខាងក្រៅដើម្បីធ្វើការអាន វិភាគ និងសម្រេចចិត្ត។ ហើយដើម្បីឱ្យរបាយការណ៍ហិរញ្ញវត្ថុមានភាពត្រឹមត្រូវ និងច្បាស់លាស់ គប្បីអនុវត្តតាមស្តង់ដាគណនេយ្យ(US GAAP) ស្តង់ដាទាក់ទងរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ(IAS/IFRS) និងស្តង់ដាទាក់ទងរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា(CIFRS)។ ដូច្នេះរបាយការណ៍ហិរញ្ញវត្ថុ គឺត្រូវការធ្វើសវនកម្មពីស្ថាប័នសវនកម្មឯករាជ្យណាមួយ មានការទទួលស្គាល់ពីសាធារណៈ(CPAs) ដែលមានជំនាញច្បាស់លាស់ ដើម្បីស្វែងរកចំណុចខ្វះខាត និងកែលម្អសម្រាប់អនុវត្ត។ ចំពោះរបាយការណ៍ហិរញ្ញវត្ថុទទួលបានមតិល្អ ឬមិនល្អ គឺអាស្រ័យតាមការគ្រប់គ្រងប្រព័ន្ធផ្ទៃក្នុងរបស់អង្គភាព។ ដោយយោងតាមការរៀបរាប់ខាងលើអំពីប្រយោជន៍នៃការធ្វើសវនកម្ម ក្រុមនាងខ្ញុំសង្កេតឃើញថាធនាគារវឌ្ឍនៈអាស៊ីចំកាត់ គឺជាធនាគារមួយដែលបានផ្តល់សេវាកម្មលើវិស័យធនាគារឈានមុខគេនៅកម្ពុជា ហើយក៏ជាធនាគារដែលបានបង្ហាញពីរបាយការណ៍ហិរញ្ញវត្ថុជូនសាធារណជនជារៀងរាល់ត្រីមាស និងប្រចាំឆ្នាំ។

អាស្រ័យហេតុនេះហើយ ទើបក្រុមរបស់នាងខ្ញុំបានធ្វើការរៀបចំ និងចងក្រងនូវឯកសារស្រាវជ្រាវនេះឡើងដែលស្តីពី"**ការធ្វើសវនកម្មក្រុមហ៊ុនឌីឡយ៍លើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់**" ក្នុងន័យសិក្សា និងចែករំលែកនូវចំណេះដឹងទាក់ទងនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលជា

ស្ថានសម្រាប់ឱ្យអ្នកប្រើប្រាស់ទទួលបានទំនុកចិត្ត និងអាចធ្វើការសម្រេចចិត្តផ្នែកវិនិយោគដោយ ចៀសវាង នូវហានិភ័យផ្សេងៗ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការធ្វើសវនកម្ម ជាពិសេសគឺការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ គឺពិតជាសំខាន់ និងចាំបាច់ណាស់នៅក្នុងក្រុមហ៊ុន។ ការធ្វើសវនកម្ម គឺជាការតាមដាន និងត្រួតពិនិត្យទៅលើសកម្មភាពផ្សេងៗរបស់ក្រុមហ៊ុន ព្រមទាំងជួយទប់ស្កាត់ការកើតឡើងនូវកំហុសចេតនា ឬអចេតនានៅក្នុងក្រុមហ៊ុនមួយនោះ។ មុខងាររបស់សវនករផ្ទៃក្រៅ គឺអាចជួយកាត់បន្ថយនូវកំហុស និងការក្លែងបន្លំផ្សេងៗនៅក្នុងក្រុមហ៊ុន។ ដូច្នេះកត្តាមួយដែលសំខាន់ក្នុងការជួយធានាថាក្រុមហ៊ុនមានភាពរឹងមាំផ្នែកហិរញ្ញវត្ថុបានតទៅមុខទៀតគឺចាំបាច់គួរតែមានការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។

ដើម្បីមានភាពងាយស្រួលក្នុងការប្រមូលគោលគំនិតសម្រាប់ធ្វើការស្រាវជ្រាវ ក្រុមសារណាស្រាវជ្រាវនាងខ្ញុំនឹងធ្វើការសិក្សាស្រាវជ្រាវពីរចំណុចដូចខាងក្រោម៖

១. តើដំណើរការនៃការធ្វើសវនកម្មរបស់ក្រុមហ៊ុន Deloitte មកលើរបាយការណ៍ហិរញ្ញវត្ថុធនាគារវឌ្ឍនៈអាស៊ីចំកាត់អនុវត្តយ៉ាងដូចម្តេច?

២. តើធនាគារវឌ្ឍនៈអាស៊ីចំកាត់ទទួលបានផលប្រយោជន៍អ្វីខ្លះបន្ទាប់ពីក្រុមហ៊ុន Deloitte បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរួច?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺមានសារៈសំខាន់ទៅលើប្រធានបទ "ការធ្វើសវនកម្មក្រុមហ៊ុនឌីឡូយធ៍ លើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់" គឺដើម្បីរួមចំណែកនូវក្នុងការផ្តល់យោបល់ព្រមទាំងអនុសាសន៍ទៅលើចំណុចមួយចំនួនដែលត្រូវកែលម្អ និងធ្វើការស្វែងយល់បន្ថែមនូវចំណុចមួយចំនួនដូចខាងក្រោម៖

- យល់ដឹងអំពីដំណើរការនៃការធ្វើសវនកម្មរបស់ក្រុមហ៊ុន Deloitte លើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់
- យល់ដឹងពីផលប្រយោជន៍សម្រាប់ធនាគារ ក្រោយពេលធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ
- វិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ
- បង្កើនចំណេះដឹងដល់ខ្លួនឯង
- រក្សាទុកជាឯកសារដល់និស្សិតជំនាន់ក្រោយជាប្រយោជន៍ក្នុងការស្រាវជ្រាវ។

## ១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់នៃការស្រាវជ្រាវ

ក្រុមយើងខ្ញុំ ផ្តោតសំខាន់ទៅលើការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ដែលមានទីតាំងស្ថិតនៅអគារលេខ១៤១ ១៤៦ ១៤៨ ១៤៨ អា អា បេសេ ដេ និង ១៦២ អា មហាវិថី ព្រះសីហនុ និងផ្ទះលេខ ១៥ និង១៥៣ អា បេសេ ផ្លូវលេខ២៧៨ និងផ្ទះលេខ២១៧១ ផ្លូវត្រសក់ផ្អែម ភូមិទី៤ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

### ១.៤.២ វិសាលភាពនៃការសិក្សាស្រាវជ្រាវ

យើងឃើញថា នៅតាមបណ្តាធនាគារវឌ្ឍនៈអាស៊ីចំកាត់ មានការរីកលូតលាស់យ៉ាងឆាប់រហ័សនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះវិភាគបានគ្រប់ជ្រុងជ្រោយ ទៅលើវិសាលភាពនៃការសិក្សាស្រាវជ្រាវក្នុងការធ្វើសវនកម្មផ្ទៃក្នុងរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ទើបបានជាក្រុមរបស់យើងខ្ញុំលើកយកតែទិន្នន័យក្នុងឆ្នាំ២០២៣ ដល់ឆ្នាំ២០២៤ របស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ធ្វើការស្រាវជ្រាវតែប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

### ១.៥.១ វិធីសាស្ត្រដែលបានយកមកប្រើប្រាស់ក្នុងការសរសេរ

ការស្រាវជ្រាវត្រូវបានប្រើវិធីសាស្ត្រគុណវិស័យ (Qualitative methods) ដោយផ្តោតជាចម្បងលើការវិភាគទិន្នន័យ និងឯកសារដែលបានមកពីធនាគារវឌ្ឍនៈអាស៊ីចំកាត់ ដែលពាក់ព័ន្ធទៅនឹងប្រធានបទ ដើម្បីយកមកវិភាគ និងធ្វើការសិក្សាស្រាវជ្រាវ ក្នុងគោលបំណងបញ្ជាក់អំពីប្រសិទ្ធភាពគ្រប់គ្រងនៃដំណើរការផលិត។

**សម្រាប់សំណួរទី១** ត្រូវបានប្រមូលតាមគុណវិស័យតាមរយៈទិន្នន័យ និងឯកសារដែលបានមកពី ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ដើម្បីយកមកបកស្រាយទៅលើការអនុវត្តវិធីសាស្ត្រ និងមានកត្តារួមផ្សំអ្វីខ្លះ ទើបអាចឱ្យការគ្រប់គ្រងដំណើរការធ្វើសវនកម្មមានប្រសិទ្ធភាពខ្ពស់បំផុត។

**សម្រាប់សំណួរទី២** ត្រូវបានប្រមូលតាមបែបគុណវិស័យ តាមរយៈទិន្នន័យ និងឯកសារដែលបានមកពីធនាគារវឌ្ឍនៈអាស៊ីចំកាត់ដើម្បីយកមកបកស្រាយទៅលើលទ្ធផល និងផលប្រយោជន៍ ដែលទទួលបានពីប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការនៃការធ្វើសវនកម្ម។

### ១.៥.២ វិធីសាស្ត្រប្រមូលទិន្នន័យ

ការស្រាវជ្រាវត្រូវបានប្រើវិធីសាស្ត្រគុណវិស័យ (Qualitative methods) ដោយផ្តោតជាចម្បង លើការវិភាគទិន្នន័យបន្ទាប់បន្សំដែលបានមកពីប្រភពគេហទំព័រចំនួន៥ IFRS , IASB due process, wikipedia.org, journal of accountancy និង fasb.org ដែលពាក់ព័ន្ធនឹងប្រធានបទ ដើម្បីយកមក វិភាគក្នុងគោលបំណងបញ្ជាក់ពីការអភិវឌ្ឍ និងការវិវត្តនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។

**សម្រាប់សំណួរទី១** ត្រូវបានប្រមូលតាមគុណវិស័យបានមកពី ប្រភពគេហទំព័រចំនួន២ IFRS និងIASB due process ដើម្បីយកមកដោះស្រាយទៅលើការអភិវឌ្ឍនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ អន្តរជាតិ និងការវិភាគទិន្នន័យបន្ទាប់បន្សំ ធ្វើតាមការវិភាគរកប្រធានបទ (Thematic analysis) តាមរយៈការវិភាគរកប្រធានបទដើម្បីសំយោគឯកសារដែលបានមកពី គេហទំព័រទាំងពីរក្នុងគោលបំណង បញ្ជាក់ពីការអភិវឌ្ឍនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។

**សម្រាប់សំណួរទី២** ត្រូវបានប្រមូលតាមគុណវិស័យបានមកពី ប្រភពគេហទំព័រចំនួន៣ wikipedia.org, journal of accountancy, fasb.org ដើម្បីអាចដោះស្រាយទៅលើការវិវត្តនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ និងការវិភាគទិន្នន័យបន្ទាប់បន្សំធ្វើតាមការវិភាគរកប្រធានបទ (Thematic analysis) តាមរយៈការវិភាគរកប្រធានបទដើម្បីសំយោគឯកសារដែលបានមកពី គេហទំព័រ ទាំងបីក្នុងគោលបំណងបញ្ជាក់ពីការវិវត្តនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

បន្ទាប់ពីបានធ្វើការស្រាវជ្រាវអស់រយៈពេលមួយរយៈ ទៅលើរបាយការណ៍ស្រាវជ្រាវមួយនេះ យើងសង្កេតឃើញថារបាយការណ៍នេះមានសារៈសំខាន់ជាច្រើនយ៉ាងដូចជា៖

**១. ចំពោះក្រុមនាងខ្ញុំ**

- ធ្វើឱ្យក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងបន្ថែមអំពីការស្រាវជ្រាវ និងការចងក្រងដើម្បីបានជារបាយការណ៍ដ៏មានសារៈសំខាន់នេះ យល់ដឹងកាន់តែច្រើនថែមទៀតអំពី ដំណើរការនៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុបន្ថែមលើទ្រឹស្តី ដែលបានសិក្សាកន្លងមក
- បង្កើនសមត្ថភាពលើការស្រាវជ្រាវ ការវិភាគ ការពិចារណា និងដោះស្រាយរាល់បញ្ហាផ្សេងៗ
- ពង្រីកចំណេះដឹងបន្ថែមទៅលើទ្រឹស្តី ដែលបានសិក្សាស្រាវជ្រាវនៅក្នុងសាលា
- យល់ដឹងពីភាពខ្លាំង និងភាពខ្សោយរបស់ខ្លួន
- ទទួលបានអនុសាសន៍កែប្រែចំណុចខ្សោយ
- រក្សាទុកជាឯកសារមួយសម្រាប់អ្នកប្រើប្រាស់ក៏ដូចជានិស្សិតជំនាន់ក្រោយ។

**២. ចំពោះធនាគារ**

- ជាឱកាសដល់ធនាគារ ដែលអាចធ្វើការអភិវឌ្ឍ និងទទួលបានការផ្សព្វផ្សាយបែបប្រយោលទៅកាន់សាធារណៈជនតាមរយៈការស្រាវជ្រាវរបស់និស្សិត។
- បន្ថែមនៅទំនុកចិត្តពីសំណាក់អ្នកប្រើប្រាស់ ការជឿជាក់ និងទុកចិត្តកាន់តែខ្លាំងទៅលើធនាគារ។

**៣. ចំពោះសាធារណជន និងសង្គមជាតិ**

- ការពារពីការលួចលាក់ និងអំពើពុករលួយផ្សេងៗ បន្ទាប់ពីសវនករឯករាជ្យបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុ។
- ជួយបង្កើនទំនុកចិត្តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មរួចដល់អ្នកវិនិយោគ ដើម្បីដាក់ការវិនិយោគ។
- គាំទ្រលើការគ្រប់គ្រងរបស់រដ្ឋាភិបាល ដែលអាចប្រើព័ត៌មានតាមរយៈរបាយការណ៍ហិរញ្ញវត្ថុ និងទិន្នន័យពីការធ្វើសវនកម្ម ដើម្បីរៀបចំគោលនយោបាយហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបែងចែកជាប្រាំជំពូកដូចខាងក្រោម៖

**ជំពូកទី១ សេចក្តីផ្តើម៖** និយាយពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវជាដើម។

**ជំពូកទី២ លំនាំបញ្ហានៃការស្រាវជ្រាវ៖** សរសេរពីស្ថានភាពទូទៅ ផែនការដំណើរការជាក់ស្តែងនៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសវនករឯករាជ្យ គឺក្រុមហ៊ុន Deloitte និងផលប្រយោជន៍មួយចំនួន បន្ទាប់ពីការធ្វើសវនកម្មរួចលើរបាយការណ៍ហិរញ្ញវត្ថុដែលធនាគារវឌ្ឍនៈអាស៊ីចំកាត់ទទួលបាន។

**ជំពូកទី៣ លទ្ធផលនៃការស្រាវជ្រាវ៖** ស្ថានភាពទូទៅរបស់ប្រធានបទមានដូចជា៖ ប្រវត្តិ ចក្ខុវិស័យ បេសកកម្ម គោលដៅ និងឆ្លើយសំណួរដែលបានចោទសួរនៅជំពូកទីមួយ។

**ជំពូកទី៤ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ៖** បង្ហាញពីទិន្នន័យ និងព័ត៌មានមួយចំនួនដែលបានស្រាវជ្រាវដើម្បីធ្វើការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រធានបទ។

**ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍៖** លើកយកភាពខ្លាំង ភាពខ្សោយរបស់ប្រធានបទមកធ្វើការសន្និដ្ឋាន និងផ្តល់អនុសាសន៍។

# ជំពូកទី២
# ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

## ២.១ លក្ខណៈទូទៅនៃការធ្វើសវនកម្ម

ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ជាច្បាប់រៀបចំអង្គការដែលមានគោលបំណងបង្កើតនូវអាជ្ញាធរសវនកម្មជាតិមួយ ដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ។ អាជ្ញាធរសវនកម្មជាតិគឺមានតួនាទីចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រដ្ឋាភិបាល ក្នុងនោះរួមមានការធ្វើសវនកម្មលើកិច្ចបញ្ជីការគណនេយ្យ គណនី ប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាស្ថាប័នគ្រប់គ្រង ដោយអនុលោមតាមស្តង់ដារនៃការធ្វើសវនកម្មទូទៅ និងតាមស្តង់ដារនៃការធ្វើសវនកម្មរបស់រាជរដ្ឋាភិបាល ។

ស្ថាប័នគ្រប់គ្រងក្នុងនោះរួមមាន បណ្តាក្រសួង ស្ថាប័នភ្នាក់ងារ អាជ្ញាធរធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋចម្រុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលខេត្ត-ក្រុង រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗទៀតដែលរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទានរួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនស្វែងរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជនផងដែរ។

អាជ្ញាធរសវនកម្មជាតិក៏មានភារកិច្ច ត្រូវធ្វើរបាយការណ៍នៃសវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងជូនទៅរដ្ឋាភិបាលដើម្បីជ្រាបជាព័ត៌មាន[1]។

### ២.១.១ និយមន័យសវនកម្ម

**និយមន័យទី១៖** សវនកម្ម គឺជាមុខវិជ្ជាមួយបែបវិទ្យាសាស្ត្រដែលសិក្សាពី ការតាមដានឆែកឆេរ ស៊ើបអង្កេត ពិនិត្យផ្ទៀងផ្ទាត់ និងវាយតម្លៃទៅលើដំណើរការអាជីវកម្មរបស់អង្គភាពមួយ ព្រមទាំងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីធានាសម្រេចបានគោលបំណងរបស់អង្គភាពដែលចង់បាន បន្ទាប់មករៀបចំជារបាយការណ៍ជូនអ្នកប្រើប្រាស់ដើម្បីធ្វើការវិភាគ និងសម្រេចចិត្ត[2]។

**និយមន័យទី២៖** សវនកម្ម គឺត្រូវធ្វើឡើងដោយពឹងផ្អែកលើវិធីសាស្ត្រជម្រើសដោយចៃដន្យ ដូច្នេះមិនមែនមានន័យថារបាយការណ៍សវនកម្ម គឺមិនមានកំហុសនោះទេ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គោលដៅសំខាន់ គឺធ្វើយ៉ាងណាកាត់បន្ថយកំហុសឆ្គងឱ្យនៅតិចជាងអប្បបរមា ដើម្បីធ្វើឱ្យព័ត៌មានដែលបានបង្ហាញអាចជឿទុកចិត្តបាន។ នៅក្នុងផ្នែកគណនេយ្យហិរញ្ញវត្ថុនិងសវនកម្ម គឺជាការវាយតម្លៃឯករាជ្យមួយទៅលើរបាយការណ៍ហិរញ្ញវត្ថុ ក្នុងគោលបំណងបញ្ជាក់ពីភាពត្រឹមត្រូវ ដែលបានធ្វើការកត់ត្រាលើកឡើងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងបានបង្ហាញដោយអ្នកគ្រប់គ្រងរបស់ស្ថាប័នអង្គភាព ឬក្រុមហ៊ុនណាមួយ។ នាពេលបច្ចុប្បន្ន សវនកម្មត្រូវបានគេប្រើជាទូទៅ និងមាននិយមន័យថា ជាការត្រួតពិនិត្យដោយលម្អិត និងពិនិត្យឡើងវិញនូវប្រព័ន្ធដំណើរការ និងទិន្នផល។

[1] ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ: (២៣/កុម្ភៈ/២០២៤). *ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា*.ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ មាត្រា១, មាត្រា២ និងមាត្រា១៤

[2] វិទ្យាស្ថានវ៉ាន់ដា. (០៨/កម្ភៈ/២០២៤). *សៀវភៅសវនកម្ម*. បោះពុម្ពលើទី១១. ទំព័រទី៣៧. ចំណុច៥.១. ភ្នំពេញ

**និយមន័យទី៣៖** សវនកម្ម គឺជាការវាយតម្លៃអំពីមនុស្ស ស្ថាប័ន ប្រព័ន្ធដំណើរការគម្រោង ឬផលិតផលណាមួយ។ សវនកម្មត្រូវបានធ្វើឡើងដើម្បីស្រាវជ្រាវស្វែងយល់អំពីសុពលភាព និងគុណភាពដែលអាចជឿទុកចិត្តបាននៃព័ត៌មាន និងផ្តល់នូវការប៉ាន់ស្មានអំពីប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង។ សវនកម្មត្រូវបានចាត់ថ្នាក់ជាពីរ គឺសវនកម្មផ្ទៃក្នុង និងសវនកម្មផ្ទៃក្រៅដែលអាស្រ័យទៅលើទំនាក់ទំនងរវាងអ្នកចូលរួម។ សវនកម្ម គឺជាសកម្មភាពផ្ទៀងផ្ទាត់នៅនឹងកន្លែងដូចជាការត្រួតពិនិត្យ ឬការពិនិត្យដំណើរការ ប្រព័ន្ធគុណភាពដើម្បីធានានូវការអនុលោមទៅតាមតម្រូវការ។ ការធ្វើសវនកម្មមួយអាចអនុវត្តទៅអង្គភាពទាំងមូល ឬអាចមានលក្ខណៈជាក់លាក់ចំពោះដំណើរការ ឬដំហានផលិត។ ដូច្នេះ និយមន័យសវនកម្មត្រូវបានកំណត់ថា គឺជាដំណើរការនៃការតាមដាន និងធែកធេរដើម្បីប្រមូលនូវភស្តុតាងសវនកម្មទៅលើការធានាអះអាងអំពីព្រឹត្តិការណ៍ និងសកម្មភាពសេដ្ឋកិច្ច ដើម្បីបញ្ជាក់ឱ្យឃើញនូវកម្រិតឆ្លើយតបរវាងការអះអាងរបស់អ្នកគ្រប់គ្រង និងលក្ខណៈវិនិច្ឆ័យដែលបង្កើតឡើង ហើយចុងក្រោយផ្សព្វផ្សាយនូវលទ្ធផលនេះទៅអ្នកប្រើប្រាស់ដែលពាក់ព័ន្ធ[3]។

### ២.១.២ ប្រវត្តិសវនកម្ម

ពាក្យសវនកម្ម"សវនកម្ម"ត្រូវបានមកពីពាក្យឡាតាំង"សវនកម្ម"ដែលមានន័យថា"ដើម្បីស្តាប់" ពីព្រោះនៅសម័យបុរាណសវនករបានស្តាប់របាយការណ៍ផ្ទាល់មាត់របស់មន្ត្រីទទួលខុសត្រូវចំពោះម្ចាស់ ឬអ្នកដែលមានអំណាច ហើយបានបញ្ជាក់ពីភាពត្រឹមត្រូវនៃរបាយការណ៍។ ប៉ុន្មានឆ្នាំមកនេះ តួនាទីសវនករបានវិវត្តន៍ដើម្បីផ្ទៀងផ្ទាត់កំណត់ត្រាដែលបានសរសេរ។

ការអនុវត្តសវនករមុនៗ ទោះបីមិនសូវមានឯកសារអំពីអត្ថិភាពនៃសវនកម្មក៏ដោយ សវនកម្មត្រូវបានគេរកឃើញថាមាននៅក្នុងអរិយធម៌បុរាណនៃប្រទេសចិន អេហ្ស៊ីប និងក្រិចក្នុងទម្រង់នៃសកម្មភាពត្រួតពិនិត្យបុរាណ។ សកម្មភាពត្រួតពិនិត្យ ដែលត្រូវបានរកឃើញនៅក្នុងប្រទេសក្រិចបុរាណហាក់ដូចជាប្រហាក់ប្រហែលទៅនឹងសវនកម្មសម័យបច្ចុប្បន្ន។

នៅក្នុងឆ្នាំ១៤៩៤ Luca Pacioli បានបោះពុម្ពសៀវភៅស្តីពីប្រព័ន្ធគណនេយ្យទ្វេដងនៃគណនេយ្យដែលប្រើប្រាស់ដោយពាណិជ្ជករនៅទីក្រុង Venice ប្រទេសអ៊ីតាលី។ នេះគឺជាសៀវភៅដំបូងស្តីពីគណនេយ្យសវនកម្មទំនើបបានចាប់ផ្តើមនៅក្នុងឆ្នាំ១៨៤៤ នៅពេលដែលសភាអង់គ្លេសបានអនុម័តច្បាប់រួមគ្នារបស់ក្រុមហ៊ុនភាគហ៊ុន។ សម្រាប់សកម្មភាពដំបូង ដែលនាយកតម្រូវឱ្យរាយការណ៍ទៅម្ចាស់ភាគហ៊ុនតាមរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរបាយការណ៍តុល្យការ។ នៅក្នុងឆ្នាំ១៨៤៤ សវនករមិនបាច់ជាសវនករ ឬឯករាជ្យទេ ប៉ុន្តែនៅក្នុងឆ្នាំ១៩០០ ច្បាប់ក្រុមហ៊ុនថ្មីត្រូវបានអនុម័តដែលតម្រូវឱ្យមានសវនករឯករាជ្យ។

សមាគមគណនេយ្យករសាធារណៈដំបូងបង្អស់ គឺសមាគមគណនេយ្យករនៅអេឌីនបឺក ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៨៥៤។ សមាគមគណនេយ្យករសាធារណៈអាមេរិកកាំង ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៨៨៧ ដែលក្រោយមកក្លាយជាសាកលវិទ្យាល័យគណនេយ្យករសាធារណៈអាមេរិក (AICPA)។ រហូត[4] មកដល់ឆ្នាំ១៩៣០ សវនកម្មត្រូវបានតម្រង់ទិសប្រតិបត្តិការគឺផ្តោតលើនីតិវិធីដែលត្រូវបានអនុវត្ត ដើម្បីដំណើរការប្រតិបត្តិការ។ នីតិវិធីទាំងនេះ ភាគច្រើនពឹងផ្អែកលើភស្តុតាងផ្ទៃក្នុង។ ការអនុវត្តរបស់សហរដ្ឋអា

[3] ចាន់ ស្រីនិច, ងម ឆេងអ៊ិន, ផល សុភាព, ម៉ិញ ចាន់ណា. (បោះពុម្ពឆ្នាំ២០២២). *ការធ្វើសវនកម្មផ្ទៃក្នុងរបស់ក្រុមហ៊ុន កូកាកូឡា នៅតំបន់សេដ្ឋកិច្ចពិសេស.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី១៩. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី៥. ភ្នំពេញ. ***VIA.013.234***

[4] LinkedIn. Lavneet Bansal. (2017, November 17). *A Brief History of Audit.* Retrieved February, 5 2025 from https://www.linkedin.com/pulse/brief-history-auditing-lavneet-bansal

មេរិកបានវិវត្តន៍តាំងពីសតវត្សទី១៩ ឆ្លោះទៅដំណើរការនៃការប្រមូលភស្តុតាងដែលទាក់ទងនឹងទ្រព្យសម្បត្តិ និងបំណុល ឬអ្វីដែលមានការយល់ច្រឡំយ៉ាងទូលំទូលាយ ដែលបានរួមចំណែកដល់ការដួលរលំនៃផ្សារភាគហ៊ុននៅក្នុងឆ្នាំ១៩២៩ ។ សកម្មភាពមូលបត្ររបស់សហរដ្ឋអាមេរិកនៅក្នុងឆ្នាំ១៩៣៣ និងឆ្នាំ១៩៣៤ បានបង្កើតគណៈកម្មការមូលបត្រ (SEC) ដែលត្រូវបានគ្រប់គ្រងលើការដោះដូរភាគហ៊ុនធំៗនៅសហរដ្ឋអាមេរិក។ ច្បាប់ទាំងនេះមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការធ្វើសវនកម្មនៅជុំវិញពិភពលោក។

ក្រុមហ៊ុនដែលមានបំណងធ្វើពាណិជ្ជកម្មភាគហ៊ុននៅផ្សារភាគហ៊ុនញូវយ៉ក ឬផ្សារភាគហ៊ុនអាមេរិកត្រូវបានតម្រូវឱ្យចេញរបាយការណ៍ប្រាក់ចំណូលក៏ដូចជាតារាងតុល្យការ។ ដូចគ្នានេះផងដែរ ដោយសារតែបញ្ហាមុនៗជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុមិនត្រឹមត្រូវនៃទសវត្សរ៍ឆ្នាំ១៩២០ ការសង្កត់ធ្ងន់បានប្តូរទៅជាភាពយុត្តិធម៌នៃការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ និងតួនាទីរបស់សវនករ គឺដើម្បីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការបង្ហាញ។

ឆ្នាំ១៩៦០-១៩៩០ ភារកិច្ចរបស់សវនករក្នុងចំណោមអ្នកផ្សេងទៀត គឺត្រូវធានាថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញភាពត្រឹមត្រូវ។ តួនាទីរបស់សវនករទាក់ទងនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុជាទូទៅនៅតែដដែលដូចកាលពីមុន។ នៅទសវត្សឆ្នាំ១៩៧០ ការផ្លាស់ប្តូរវិធីសាស្ត្រសវនកម្មត្រូវបានគេសង្កេតឃើញពី "ការផ្ទៀងផ្ទាត់ប្រតិបត្តិការនៅក្នុងសៀវភៅ" ទៅ "ការពឹងផ្អែកលើប្រព័ន្ធ"។ ការផ្លាស់ប្តូរបែបនេះគឺដោយសារតែការកើនឡើងនូវចំនួនប្រតិបត្តិការ ដែលបណ្តាលមកពីការបន្តកើនឡើងនូវទំហំ និងភាពស្មុគស្មាញរបស់ក្រុមហ៊ុន ដែលវាទំនងសម្រាប់សវនករដើរតួក្នុងការផ្ទៀងផ្ទាត់ប្រតិបត្តិការ។ ជាលទ្ធផលសវនករនៅក្នុងរយៈពេលនេះបានដាក់ការពឹងផ្អែកខ្ពស់ ទៅលើការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុននៅក្នុងនីតិវិធីសវនកម្មរបស់ពួកគេ។ នៅពេល ដែលការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុន មានប្រសិទ្ធភាព សវនករកាត់បន្ថយកម្រិតនៃការធ្វើតេស្តលម្អិតលើរបាយការណ៍។

នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ មានការកែទម្រង់មួយនៅក្នុងវិធីសាស្ត្ររបស់សវនករដែលការវាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវបានគេរកឃើញថា ជាដំណើរការដែលមានតម្លៃថ្លៃ។ ដូច្នេះសវនករបានចាប់ផ្តើមកាត់បន្ថយប្រព័ន្ធការងាររបស់ពួកគេ និងប្រើប្រាស់នីតិវិធីវិភាគឱ្យកាន់តែប្រសើរ។ ការបន្ថែមផ្នែកនេះ គឺជាការអភិវឌ្ឍអំឡុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ នៃការធ្វើសវនកម្មផ្អែកលើហានិភ័យ។ ការធ្វើសវនកម្មផ្អែកលើហានិភ័យ គឺជាវិធីសាស្ត្រសវនកម្ម ដែលសវនករនឹងផ្តោតលើតំបន់ទាំងនោះដែលទំនងជាមានកំហុស។ នៅដើមទសវត្សរ៍ឆ្នាំ២០០០ មានរឿងអាស្រូវគណនេយ្យដូចជា WorldCom, Enron, Tyco ជាដើម។ ដើម្បីឆ្លើយតបទៅនឹងការដួលរលំរបស់ Eron ច្បាប់ Sarbanes-Oxley ឆ្នាំ២០០២ ត្រូវបានអនុម័តដែលនាំមកនូវបទប្បញ្ញត្តិគណនេយ្យភាពផ្សេងៗសម្រាប់ការគ្រប់គ្រង និងសវនករ។ Sarbanes-Oxley បានពង្រីកភារកិច្ចរបស់សវនករដើម្បីធ្វើសវនកម្ម ភាពគ្រប់គ្រាន់នៃការគ្រប់គ្រងផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុ។ រឿងអាស្រូវគណនេយ្យទាំងនេះ ក៏នាំឱ្យមានការធ្លាក់ចុះរបស់ Arthur Andersen ដែលជាក្រុមហ៊ុនសវនកម្មធំមួយនៅគ្រានោះ ដោយសារតួនាទីរបស់ខ្លួននៅក្នុងរឿងអាស្រូវ អេនរុន (Enron)។ ទោះបីជាគោលបំណងសវនកម្មរួមនៅក្នុងរយៈពេលបច្ចុប្បន្ននៅតែដដែរ ពោលគឺការផ្តល់ប្រាក់កម្ចីដល់របាយការណ៍ហិរញ្ញវត្ថុ ការផ្លាស់ប្តូរសំខាន់ៗ

ត្រូវបានធ្វើឡើងចំពោះការអនុវត្តសម្រាប់សវនកម្ម ដែលជាលទ្ធផលនៃកំណែទម្រង់យ៉ាងទូលំទូលាយ នៅក្នុងប្រទេសផ្សេងៗ[5]។

**២.១.៣ ប្រភេទសវនកម្ម**

សវនកម្មត្រូវបានបែងចែកជា ២ ប្រភេទមាន៖ សវនកម្មផ្ទៃក្នុង និងសវនកម្មផ្ទៃក្រៅ។

**១. សវនកម្មផ្ទៃក្នុង (Internal Auditing)**

សវនកម្មផ្ទៃក្នុង (Internal Auditing) គឺជាមុខវិជ្ជាមួយបែបវិទ្យាសាស្ត្រ ដែលសិក្សាលម្អិតពីរបៀបតាមដាន ឆែកឆេរ ប្រមូលភស្តុតាង រួចវាយតម្លៃថា តើអ្នកគ្រប់គ្រងមានបានអនុវត្តតាមគោលនយោបាយ និងនីតិវិធីគ្រប់គ្រងផ្ទៃក្នុង ដើម្បីសម្រេចបានគោលដៅទាំង៣យ៉ាង ដូចដែលក្រុមប្រឹក្សាភិបាលអនុម័តជាមុនហើយឬនៅ? រួចចេញរបាយការណ៍សវនកម្មផ្ទៃក្នុងជូនអ្នកប្រើប្រាស់ខាងក្នុង ដើម្បីធ្វើការសម្រេចចិត្ត និងចាត់វិធានការ (Taking in acting)។

សវនកម្មផ្ទៃក្នុង គឺជាសវនកម្មដែលស្ថិតនៅក្នុងអង្គភាពមានតួនាទីសំខាន់២គឺ៖

- សវនកម្មលើប្រតិបត្តិការ/គ្រប់គ្រង (Operational / Management Audit)
- សវនកម្មលើច្បាប់ និងលិខិតបទដ្ឋាននានា (Compliance Audit)[6] ។

សវនករផ្ទៃក្នុងដើម្បីធានាឱ្យបាននូវឯករាជ្យភាព មិនលំអៀង និងជាសកម្មភាពពិគ្រោះយោបល់ដែលបង្កើតឡើងដើម្បីវាយតម្លៃ និងធ្វើឱ្យប្រតិបត្តិការរបស់អង្គភាពកាន់តែប្រសើរ សវនករត្រូវអនុវត្តតាមគោលការណ៍ និងវិធានដូចខាងក្រោម៖

១. <u>គោលការណ៍</u>

ក. ភាពសុចរិត៖ ភាពសុចរិតរបស់សវនករបង្កើននូវការទុកចិត្ត និងជាមូលដ្ឋានបម្រើឱ្យការជឿជាក់លើការវិនិច្ឆ័យរបស់សវនករ។

ខ. ភាពមិនលំអៀង៖ សវនករត្រូវរក្សាភាពមិនលំអៀងលើវិជ្ជាជីវៈកម្រិតខ្ពស់ ក្នុងការប្រមូល ការវាយតម្លៃ និងរាយការណ៍ព័ត៌មានអំពីសកម្មភាព ឬដំណើរការដែលបានពិនិត្យ។ សវនករធ្វើការវាយតម្លៃយ៉ាងត្រឹមត្រូវនៅគ្រប់កាលៈទេសៈទាំងអស់ ដោយពុំគិតផលប្រយោជន៍ផ្ទាល់ខ្លួន និងឥទ្ធិពលអ្នកដទៃនៅក្នុងការវិនិច្ឆ័យនោះទេ។

គ. ការសម្ងាត់៖ សវនករគោរពតម្លៃ និងកម្មសិទ្ធិនៃព័ត៌មានដែលបានទទួល និងមិនផ្សព្វផ្សាយព័ត៌មានដោយគ្មានការអនុញ្ញាត លើកលែងតែមានកាតព្វកិច្ចក្នុងផ្លូវច្បាប់ ឬ ក្នុងវិជ្ជាជីវៈក្នុងការផ្សព្វផ្សាយព័ត៌មាននោះ។

ឃ. សមត្ថភាព៖ សវនករប្រើចំណេះដឹង ជំនាញ បទពិសោធន៍ដែលចាំបាច់ក្នុងការអនុវត្តសកម្មភាពសវនកម្ម[7]។

២. <u>វិធាន</u>

**ក. ភាពសុចរិត**

- ត្រូវអនុវត្តការងាររបស់ខ្លួនដោយស្មោះត្រង់ ប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់

[5] LinkedIn. (2024, February 15). *A Brief History of Audit*. Retrieved March, 12 2025, from https://www.linkedin.com/pulse/brief-history-auditing-lavneet-bansal

[6] វិទ្យាស្ថានវ៉ាន់ដា. (០៤/កុម្ភៈ/២០២៤). *សៀវភៅសវនកម្មភាគ១*. បោះពុម្ពលើកទី១០ ឆ្នាំ២០២៣ ទំព័រទី៣៧&៣៨ ចំណុច៥.១&៥.២

[7] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (២៤/កុម្ភៈ/២០២៤). *ក្រមសីលធម៌សម្រាប់សវនករផ្ទៃក្នុង*

- ត្រូវប្រតិបត្តិតាមច្បាប់ និងផ្សព្វផ្សាយព័ត៌មានដែលតម្រូវដោយច្បាប់ និងវិជ្ជាជីវៈ
- មិនត្រូវចូលរួមក្នុងសកម្មភាពមិនស្របច្បាប់ ឬ ក្នុងសកម្មភាពទាំងឡាយណា ដែលនាំឱ្យប៉ះពាល់ដល់វិជ្ជាជីវៈសវនកម្ម ឬកិត្តិយសរបស់រដ្ឋាភិបាល
- ត្រូវគោរព និងរួមចំណែកក្នុងគោលដៅស្របច្បាប់របស់រដ្ឋាភិបាល។

**ខ. ភាពមិនលំអៀង**

- មិនត្រូវចូលរួមសកម្មភាព ឬទំនាក់ទំនងដែលអាចធ្វើឱ្យប៉ះពាល់ដល់ការវាយតម្លៃប្រកបដោយភាពមិនលំអៀងរបស់ខ្លួន និងអាចប៉ះពាល់ដល់ប្រយោជន៍របស់រដ្ឋាភិបាល
- មិនត្រូវទទួលយកអ្វីដែលប៉ះពាល់ ឬលគិតថាអាចប៉ះពាល់ដល់ការវិនិច្ឆ័យតាមលក្ខណៈវិជ្ជាជីវៈរបស់ខ្លួន
- ត្រូវបង្ហាញនូវរាល់ហេតុការណ៍ជាសារវន្ត ដែលសវនករអាចដឹងថា ប្រសិនបើមិនបង្ហាញនោះទេ របាយការណ៍ស្តីពីសកម្មភាព ដែលត្រូវបានពិនិត្យ និងខុសពីការពិត។

**គ. ការសម្ងាត់**

- ត្រូវប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ និងការពារព័ត៌មានដែលបានទទួលក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន
- មិនត្រូវប្រើប្រាស់ព័ត៌មានសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន ឬផ្ទុយនឹងច្បាប់ ឬធ្វើឱ្យប៉ះពាល់ចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ឃ. សមត្ថភាព**

- ត្រូវធ្វើសវនកម្មលើសកម្មភាពណាដែលខ្លួនមានចំណេះដឹង ជំនាញ និងបទពិសោធន៍ច្បាស់លាស់
- ត្រូវអនុវត្តការងារសវនកម្មផ្ទៃក្នុង ដោយអនុលោមតាមស្តង់ដាវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង ដែលចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ត្រូវបង្កើនជំនាញ ប្រសិទ្ធភាព និងគុណភាពនៃការងាររបស់ខ្លួន[8]។

**២.សវនកម្មផ្ទៃក្រៅ**

សវនកម្មផ្ទៃក្រៅ (External Auditing) គឺជាមុខវិជ្ជាមួយបែបវិទ្យាសាស្ត្រ ដែលសិក្សាលម្អិតពីរបៀបតាមដាន ឆែកឆេរ ប្រមូលភស្តុតាង រួចវាយតម្លៃថា តើអ្នកគ្រប់គ្រងមានបានអនុវត្តតាមគោលនយោបាយ និងនីតិវិធីគណនេយ្យ ដើម្បីទទួលបាននូវរបាយការណ៍ហិរញ្ញវត្ថុគួរជាទីទុកចិត្តបាន ដូចដែលក្រុមប្រឹក្សាភិបាលបានអនុម័តជាមុនហើយឬនៅ? រួចចេញរបាយការណ៍សវនកម្មផ្ទៃក្រៅដែលមានលក្ខណៈ៤យ៉ាងគឺៈ

- Unqualified opinion - Qualified opinion
- Disclaimer opinion - Adverse opinion

សវនកម្មផ្ទៃក្រៅ (External Auditing) គឺជាសេវាសវនកម្មឯករាជ្យមិនស្ថិតនៅក្រោមអង្គភាព ឬសហគ្រាសណាឡើយ។ សវនកម្មផ្ទៃក្រៅ មានតួនាទីដ៏សំខាន់គឺការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ (Financial Statement Audit)[9]។

[8] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (២៤/កុម្ភៈ/២០២៤). *ក្រមសីលធម៌សម្រាប់សវនករផ្ទៃក្នុង*

[9] វិទ្យាស្ថានវ៉ាន់ដា. (០៤/កុម្ភៈ/២០២៤). សៀវភៅសវនកម្មភាគ១. បោះពុម្ពលើកទី១០. ឆ្នាំ២០២៣. ទំព័រទី៣៧&៣៨ ចំណុច៥.១&៥.២

សវនកម្មផ្ទៃក្រៅ គឺជាការពិនិត្យពិចារណា ឬការពិនិត្យឡើងវិញលើកិច្ចបញ្ជីការគណនេយ្យ ប្រព័ន្ធគ្រប់គ្រងកិច្ចប្រតិបត្តិការ និងការត្រួតពិនិត្យទៅលើស្ថាប័នគ្រប់គ្រង ដោយអនុលោមតាមស្តង់ដានៃការធ្វើសវនកម្មទូទៅ និងតាមស្តង់ដានៃការធ្វើសវនកម្មរបស់រដ្ឋាភិបាលដើម្បីផ្តល់ការធានាថា៖

- បណ្តាសកម្មភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ចត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវតាមរយៈសេចក្តីថ្លែងការណ៍ និងតាមរបាយការណ៍។
- បណ្តាសកម្មភាពទាំងនេះត្រូវបានអនុវត្តដោយអនុលោមតាមគោលការណ៍គណនេយ្យទូទៅ។
- ការត្រួតពិនិត្យនីតិវិធី និងការអនុវត្តដោយអនុលោមតាមច្បាប់ បទបញ្ជា កិច្ចព្រមព្រៀង ប្រព័ន្ធគ្រប់គ្រង កិច្ចសន្យា កម្មវិធីនិងលក្ខណៈវិនិច្ឆ័យផ្សេងទៀតដែលទាក់ទងដល់ចំណូល ចំណាយ និងការប្រើប្រាស់ប្រភពធនធានរបស់រាជរដ្ឋាភិបាល[10]។

## ២.២ ដំណើរការនៃការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

### ២.២.១ និយមន័យរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ គឺជារបាយការណ៍មួយប្រភេទ ដែលរៀបចំឡើងផ្អែកទៅតាមវិធីសាស្រ្តគណនេយ្យ ដើម្បីបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមួយនៅពេលកំណត់ជាក់លាក់មួយ។ វារៀបចំឡើងផ្អែកលើវិធីសាស្រ្តគណនេយ្យ មានន័យថា ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុពឹងផ្អែកទាំងស្រុង ទៅលើការកត់ត្រាទិន្នន័យរបស់គណនេយ្យនៅក្នុងបណ្តាសៀវភៅផ្សេងៗ[11]។

របាយការណ៍ហិរញ្ញវត្ថុ គឺពិតជាបានឆ្លុះបញ្ចាំងពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមួយដូចជា៖ ចំណូល ចំណាយ ទ្រព្យសកម្ម ទ្រព្យអសកម្ម និងលំហូរសាច់ប្រាក់ចូលឬចេញ។ ដូច្នេះ យើងអាចដឹងពីចំណុចខ្លាំង ចំណុចខ្សោយ និងសក្តានុពលរបស់ក្រុមហ៊ុនតាមរយៈរបាយការណ៍ហិរញ្ញវត្ថុរបស់វា[12]។

### ២.២.២ ដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុត្រូវបានគេរៀបចំឡើងនៅថ្ងៃទី៣១ ខែមីនា ឬថ្ងៃទី៣០ ខែមិថុនា ឬថ្ងៃទី៣១ ខែធ្នូជាដើម។ វាជាកំណត់ត្រាផ្លូវការនៃសកម្មភាពហិរញ្ញវត្ថុទីតាំងអាជីវកម្មរបស់មនុស្សម្នាក់ ឬអង្គភាពមួយផ្សេងទៀត។ ព័ត៌មានហិរញ្ញវត្ថុត្រូវបានបង្ហាញតាមរបៀបដែលមានរចនាសម្ព័ន្ធ និងទម្រង់ដែលងាយយល់។ របាយការណ៍ទាំងនេះរួមមានជាមូលដ្ឋានចំនួន៥ អមដោយការពិភាក្សាពីការគ្រប់គ្រង៖

១. របាយការណ៍តុល្យការ៖ ជំហរហិរញ្ញវត្ថុរបាយការណ៍ស្តីពី ទ្រព្យសកម្ម បំណុល និងម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុននៅតាមពេលវេលាដែលបានកំណត់។

[10] ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ. (២៦/កុម្ភៈ/២០២៤). *ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា* ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ មាត្រា៤

[11] ឈុនលី សុជាតា, ជឹម ស្រីថៃ, ម៉ែន រតី, ចេក សៅជី, អ៊ាន់ ស្រីអូន, អ៊ុង សារ៉ាត់. (2022). *ការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់១៩. ជំនាញគណនេយ្យហិរញ្ញវត្ថុ. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី១១. ភ្នំពេញ. *VIA.016.234*

[12] WordPress. Khem Sarith. (2024, June 29). *និយមន័យរបាយការណ៍ហិរញ្ញ.* Retrieved February, 15 2025, from https://khemsarith.wordpress.com/2016/10/05/និយមន័យរបាយការណ៍ហិរញ្ញ/

២. របាយការណ៍លទ្ធផល៖ របាយការណ៍ប្រាក់ចំណូល ប្រាក់ចំណេញ និងការខាតបង់ ប្រាក់ចំណូល ទូលំទូលាយ ឬរបាយការណ៍ចំណូល និងចំណាយ របាយការណ៍ស្តីពីប្រាក់ចំណូល ការចំណាយ និងប្រាក់ចំណេញរបស់ក្រុមហ៊ុនក្នុងរយៈពេលជាក់លាក់មួយ។
៣. របាយការណ៍បម្រែបម្រួលមូលធន៖ ស្តីពីការផ្លាស់ប្តូរភាគហ៊ុន ឬអំពីសមធម៌ ឬអំពីប្រាក់ចំណូលដែលត្រូវបានរក្សាទុកជារបាយការណ៍ការផ្លាស់ប្តូរភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងរយៈពេល ដែលបានបញ្ជាក់ណាមួយ។
៤. របាយការណ៍លំហូរសាច់ប្រាក់៖ រាយការណ៍ពីសកម្មភាពលំហូរសាច់ប្រាក់ ប្រតិបត្តិការវិនិយោគ និងផ្តល់ហិរញ្ញប្បទានក្នុងរយៈពេលកំណត់មួយ។
៥. របាយការណ៍ប្រាក់ចំណូលទូលំទូលាយពាក់ព័ន្ធ និងធាតុប្រាក់ចំណូលទូលំទូលាយផ្សេងៗទៀតដែលមិនត្រូវបានរាប់បញ្ចូលខណៈពេលដែលកំណត់ប្រាក់ចំណូលសុទ្ធ[13]។

**២.២.៣ សារៈសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ**

របាយការណ៍ហិរញ្ញវត្ថុមានសារៈសំខាន់ណាស់ ចំពោះអ្នកពាក់ព័ន្ធដូចខាងក្រោម៖

- អ្នកគ្រប់គ្រងក្រុមហ៊ុនផ្ទាល់៖ នៅក្នុងការរៀបចំនូវគម្រោងហិរញ្ញវត្ថុផ្សេងៗ ពឹងផ្អែកទាំងស្រុងលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដើម្បីអាចធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ តាមស្ថានភាពជាក់ស្តែង។
- បុគ្គល និងអង្គភាពខាងក្រៅក្រុមហ៊ុន៖ វិនិយោគិន ម្ចាស់បំណុល និងភាគីពាក់ព័ន្ធ មុននឹងធ្វើការសម្រេចចិត្តផ្សេងៗជាមួយក្រុមហ៊ុន ពួកគេត្រូវតែស្វែងយល់ពីរបាយការណ៍ហិរញ្ញវត្ថុឱ្យបានច្បាស់របស់ក្រុមហ៊ុន ដើម្បីដឹងពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់វា។
- រដ្ឋាភិបាល (Government) ៖ ភ្នាក់ងាររបស់រដ្ឋាភិបាលមានតួនាទីត្រួតពិនិត្យ និងតាមដានអំពីស្ថានភាពអាជីវកម្មរបស់ក្រុមហ៊ុនថាតើក្រុមហ៊ុនបានអនុវត្តតាមច្បាប់ដែរឬទេ? ដូចជាការកត់ត្រាការបង់ពន្ធជាដើម ដូច្នេះ គេត្រូវពឹងពាក់លើការរបាយការណ៍ហិរញ្ញវត្ថុទាំងស្រុង ។

## ២.៣ ផលប្រយោជន៍នៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ

**២.៣.១ និយមន័យរបស់ធនាគារ**

អត្ថន័យនៃពាក្យ ធនាគារ ត្រូវបានផ្តល់និយមន័យជាច្រើនតាមការយល់ឃើញផ្សេងៗពីគ្នា៖

- ធនាគារមានមុខងារ៣ ៖
  ១. មុខងារសេដ្ឋកិច្ចដែលវាបម្រើជូនអតិថិជនទាំងឡាយ
  ២. សេវាកម្មដែលវាផ្តល់ជូនអតិថិជនទាំងឡាយ
  ៣. មូលដ្ឋានស្របច្បាប់ចំពោះអត្ថិភាពរបស់វា។
- ជាប្រពៃណីមុខងាររបស់ធនាគារ គឺទទួលប្រាក់បញ្ញើពីសាធារណៈជនហើយនឹងប្រើប្រាស់វាទៅជាប្រភពដ៏សំខាន់របស់មូលនិធិ ដើម្បីបង្កើតកម្ចីអាជីវកម្ម និងកម្ចីមិនមែនអាជីវកម្ម[14]។

[13] វិទ្យាស្ថានវ៉ាន់ដា. (២៤/កុម្ភៈ/២០២៤). *សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ*. ជំនាន់១៩. VIA.013.203 ទំព័រទី១២

[14] WordPress. Khem Sarith. (2024, June 29). *និយមន័យរបាយការណ៍ហិរញ្ញវត្ថុ*. Retrieved February, 2 2025 from https://khemsarith.wordpress.com/2016/10/05/

- ក្រុមហ៊ុន គឺជានីតិបុគ្គលដែលបង្កើតឡើងដោយបុគ្គលដើម្បីចូលរួម និងដំណើរការអាជីវកម្ម ពាណិជ្ជកម្ម ឬឧស្សាហកម្ម សហគ្រាស។
- ធនាគារ គឺជាស្ថាប័នហិរញ្ញវត្ថុមួយប្រភេទដែលទទួលប្រាក់បញ្ញើ និងដើម្បីដកប្រាក់តាមតម្រូវការ (ដូចជាសរសេរមូលប្បទានបត្រ ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច) ហើយនឹងផ្តល់ឥណទានទៅឱ្យសាធារណៈជន និងអាជីវកម្ម(ផ្តល់ឥណទានដល់អាជីវកម្មឯកជនដើម្បីពង្រីកសន្និធិរបស់ទំនិញនៅក្នុងហាងរបស់ពួកគេ ឬដើម្បីទិញសម្ភារៈបរិក្ខារថ្មីៗ) [15]។

**២.៣.២ ប្រវត្តិទូទៅរបស់ធនាគារ**

វិស័យធនាគារនៅក្នុងប្រទេសកម្ពុជា គឺជាប្រព័ន្ធដែលមានពីរថ្នាក់បញ្ចូលគ្នាមានវិស័យសាធារណៈ (តំណាងដោយធនាគារជាតិនៃកម្ពុជា) និងវិស័យឯកជន រួមមានធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនដែលបានចូលរួមនៅក្នុងសកម្មភាពឥណទានជនបទ។ អនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ធនាគារទាំងអស់ត្រូវតែស្នើសុំអាជ្ញាប័ណ្ណ និងស្ថិតក្រោមការត្រួតពិនិត្យពីធនាគារជាតិនៃកម្ពុជា។ ដោយឡែក កាលពីប៉ុន្មានឆ្នាំកន្លងទៅធនាគារមួយចំនួនពុំមានដំណើរការល្អ ដោយសារការគ្រប់គ្រងមានភាពទន់ខ្សោយ ដែលធ្វើឱ្យអតិថិជនបាត់បង់ជំនឿទុកចិត្តលើប្រព័ន្ធធនាគារ។ ដើម្បីដោះស្រាយនូវស្ថានភាពនេះ ធនាគារជាតិនៃកម្ពុជាបានអនុវត្តច្បាប់ ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងបានអនុវត្តកម្មវិធីផ្តល់អាជ្ញាប័ណ្ណសាជាថ្មីដល់គ្រឹះស្ថានទាំងនោះ ។ តាមរយៈការអនុវត្តកម្មវិធីកំណែទម្រង់សាជាថ្មីនេះ ប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាបានអភិវឌ្ឍជាបន្តបន្ទាប់ និងអាចធានាបាននូវស្ថិរភាពខ្ពស់។ គិតមកត្រឹមខែធ្នូ ឆ្នាំ២០១៤ មានធនាគារពាណិជ្ជមានចំនួន៣៦ ធនាគារឯកទេស ១១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ៤០ ប្រតិបត្តិការឥណទានដែលបានចុះបញ្ជី៣៨ និងក្រុមហ៊ុនភតិសន្យាចំនួន៦ ដែលបានចូលរួមសកម្មភាពក្នុងវិស័យហិរញ្ញវត្ថុ។

ក្នុងចំណោមគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងអស់ ធនាគារពាណិជ្ជដើរតួនាទីជាអ្នកផ្តល់សេវាទូទាត់ដ៏សំខាន់បំផុត ដោយសារពួកគេទទួលបាននូវអត្ថប្រយោជន៍ផ្នែកគតិយុត្តិ និងស្ថាប័នក្នុងការទទួលបាននូវប្រាក់បញ្ញើពីសាធារណជន។ ប្រាក់បញ្ញើរបស់ធនាគារផ្តល់ជាមូលដ្ឋាន ដ៏សំខាន់សម្រាប់ប្រតិបត្តិការទូទាត់ដែលមិនប្រើប្រាស់ សាច់ប្រាក់ដូចជាការផ្ទេរឥណទាន ឥណពន្ធផ្ទាល់ និងសម្រាប់ការទូទាត់ដោយប្រើប្រាស់ប័ណ្ណទូទាត់។ ម្យ៉ាងទៀតលើសពីនេះ ធនាគារពាណិជ្ជក៏បានដាក់ឱ្យប្រើប្រាស់ និងគ្រប់គ្រងនូវហេដ្ឋារចនាសម្ព័ន្ធប្រើប្រាស់ប័ណ្ណទូទាត់ដូចជាម៉ាស៊ីន ATM និងម៉ាស៊ីនឆូតកាត (POS) ផងដែរ[16]។

**២.៣.៣ ប្រភេទរបស់ធនាគារ**

- ធនាគារពាណិជ្ជ(Commercial Banks)៖ ទទួលប្រាក់បញ្ញើ និងផ្តល់កម្ចីដល់បុគ្គល គ្រួសារ និងអង្គភាពធុរកិច្ច។
- ធនាគារសន្សំ(Saving Banks)៖ ទទួលប្រាក់បញ្ញើសន្សំ ផ្តល់កម្ចីដល់បុគ្គល និងគ្រួសារព្រមទាំងវិនិយោគលើមូលបត្រ។

---

[15] WordPress. Khem Sarith. (2016, October 05). *និយមន័យធនាគារ*. Retrieved February, 5 2025 from https: //khemsarith.wordpress.com/2016/10/05/និយមន័យធនាគារ/

[16] គេហទំព័ររបស់ធនាគារជាតិ. NBC: https://www.nbc.gov.kh/about_the_bank/working_at_the_nbc.php

- ធនាគារសហករណ៍(Cooperative Banks)៖ ផ្តល់ឥណទានដល់កសិករ អ្នកចិញ្ចឹមសត្វ ព្រមទាំងអ្នកប្រើប្រាស់សម្រាប់តម្រូវការទំនិញ និងសេវាកម្មទាំងឡាយ។
- ធនាគារនិក្ខេប(Mortgage Banks)៖ ជាធនាគារផ្តល់ឥណទានសម្រាប់ទិញផ្ទះថ្មី និងឥណទានសម្រាប់គម្រោងសាងសង់ផ្ទះ។
- ធនាគារសហគមន៍(Community Banks)៖ គឺជាប្រភេទធនាគារនៅក្នុងស្រុកមានទ្រង់ទ្រាយតូចដែលផ្តោតទៅលើសេវាសន្សំ ប្រាក់បញ្ញើ និងសេវាផ្សេងៗទៀត។
- ធនាគារកណ្តាលរូបិយវត្ថុ(Money Center Banks)៖ ធនាគាពាណិជ្ជដ៏ធំមួយនិងជាមជ្ឈមណ្ឌលហិរញ្ញវត្ថុឈានមុខគេ។
- ធនាគារវិនិយោគ(Investment Banks)៖ ផ្តល់ការប្រឹក្សាយោបល់ក្នុងការបោះផ្សាយមូលបត្រថ្មីដល់សាជីវកម្ម និងជានាទិញមូលបត្រមួយផ្នែក ឬទាំងស្រុងពីសាជីវកម្មបោះផ្សាយទាំងនោះ។
- ធនាគារពាណិជ្ជករ(Merchant Banks)៖ ផ្គត់ផ្គង់ទាំងពីរគឺ មូលធនបំណុល និងមូលធនសុទ្ធដល់អង្គភាពធុរកិច្ច។
- ធនាគារអន្តរជាតិ(International Banks)៖ គឺជាធនាគារពាណិជ្ជទាំងឡាយតំណាងដោយជាតិជាច្រើន។
- ធនាគារលក់ដុំ(Wholesale Banks)៖ គឺជាធនាគារពាណិជ្ជដ៏ធំជាងគេ ដែលបានបម្រើនូវសេវាសាជីវកម្ម និងគ្រប់គ្រង។
- ធនាគារលក់រាយ(Retail Banks)៖ គឺជាធនាគារតូចៗ ដែលបម្រើសេវាដល់អ្នកប្រើប្រាស់ដំបូង និងអង្គភាពធុរកិច្ចធន់តូច។
- ធនាគារីករបស់ធនាគារ(Banker's Banks)៖ ផ្តល់សេវាផ្សេងៗទៅឱ្យធនាគារទាំងឡាយ ដូចជាការទូទាត់មូលប្បទានបត្រ ការធ្វើពាណិជ្ជកម្មមូលបត្រ។
- ធនាគាររដ្ឋ(State Banks)៖ ជាធនាគារមានមុខងារស្ថិតនៅក្រោមអង្គធម្មនុញ្ញ ដែលកំណត់ដោយគណៈកម្មការធនាគារនៅក្នុងរដ្ឋផ្សេងៗគ្នា។
- ធនាគារធានារ៉ាប់រង(Insured Banks)៖ ការធានារ៉ាប់រងប្រាក់បញ្ញើក្នុងការសងត្រឡប់ទៅវិញ ដោយផែនការធានារ៉ាប់រងប្រាក់បញ្ញើសហព័ន្ធ។
- ធនាគារសមាជិក(Member Banks)៖ គឺជាធនាគារដែលជាសមាជិករបស់ប្រព័ន្ធនៃប្រាក់បម្រុងសហព័ន្ធ។
- ធនាគារជាសាខា(Affiliated Banks)៖ គឺជាកម្មសិទ្ធិទាំងស្រុង ឬដោយផ្នែកដោយក្រុមហ៊ុនដែលជាភាគហ៊ុនមួយ។
- ធនាគារសាកលវិទ្យាល័យ(Universal Banks)៖ ផ្តល់គ្រប់សេវាកម្មហិរញ្ញវត្ថុទាំងអស់ ដែលមាននៅក្នុងទីផ្សារនៅថ្ងៃនេះ។

- ធនាគារជាតិ (National Banks)៖ គឺជាធនាគាររបស់រដ្ឋ ដែលមានមុខងារត្រូវបានកំណត់ដោយអង្គធម្មនុញ្ញ និងជាអ្នកជំរះបញ្ជីរបស់រូបិយប័ណ្ណ[17]។

[17] WordPress. Khem Sarith. (2016, October 04). *ប្រភេទខុសៗគ្នានៃធនាគា.* Retrieved February, 5 2025 from https://khemsarith.wordpress.com/2016/10/04/

# ជំពូកទី៣
# ការធ្វើសវនកម្មក្រុមហ៊ុនឌីឡយ៍ធ៍លើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់

## ៣.១ ស្ថានភាពទូទៅរបស់ Deloitte

### ៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន Deloitte

ក្រុមហ៊ុននេះត្រូវបានបង្កើតឡើងដោយ William Welch Deloitte នៅទីក្រុងឡុងដ៍ក្នុងឆ្នាំ១៨៤៥ ហើយ បានពង្រីកទៅសហរដ្ឋអាមេរិកក្នុងឆ្នាំ១៨៩០។ វាបានរួមបញ្ចូលគ្នាជាមួយ Haskins & Sells ដើម្បីបង្កើតជា Deloitte Haskins & Sells ក្នុងឆ្នាំ១៩៧២ និងជាមួយ Touche Ross នៅឯសហរដ្ឋអាមេរិកដើម្បីបង្កើតក្រុមហ៊ុន Deloitte & Touche ក្នុងឆ្នាំ១៩៨៩ ។




Deloitte Cambodia បង្កើតឡើងនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤។ ក្រុមហ៊ុន Deloitte បាននាំមកនូវសមត្ថភាពលំដាប់ថ្នាក់ពិភពលោក និងផ្តល់សេវាកម្ម សវនកម្ម ពន្ធប្រឹក្សាព្រមទាំងការផ្តល់ប្រឹក្សាហិរញ្ញវត្ថុ ដែលមានគុណភាពខ្ពស់ដល់អតិថិជនរបស់យើង នៅគ្រប់ទីកន្លែងដែលពួកគេកំពុងតែនៅប្រកបអាជីវកម្មនៅទូទាំងពិភពលោក។ ឥឡូវនេះយើងមានប្រតិបត្តិការនៅក្នុងប្រទេសចំនួន១១ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ រួមមានប្រទេសប្រ៊ុយណេ ហ្គាំ ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម។ Deloitte គឺជាអ្នកដែលផ្តល់នូវសេវា សវនកម្ម និងការជានាឈានមុខគេនៅលើពិភពលោកទៅលើសេវាកម្ម ប្រឹក្សាយោបល់ប្រឹក្សាហិរញ្ញវត្ថុ ប្រឹក្សាហានិភ័យ ពន្ធ និងសេវាកម្មពាក់ព័ន្ធ។ បច្ចុប្បន្ន Deloitte មានមនុស្ស ប្រមាណ ៣៣០,០០០នាក់ ក្នុងជាង១៥០ប្រទេស និងដែនដី។

### ៣.១.២ ចក្ខុវិស័យ និងបេសកកម្ម គុណតម្លៃរបស់ក្រុមហ៊ុន Deloitte

- **ចក្ខុវិស័យ**

ចក្ខុវិស័យរបស់ក្រុមហ៊ុន Deloitte គឺដើម្បីក្លាយជាស្តង់ដារនៃឧត្តមភាព ដែលជាជម្រើសដ៏ល្អដំបូងរបស់អតិថិជនដែលមានទេពកោសល្យ និងងាយស្វែងរកបំផុត។ សេចក្តីថ្លែងការណ៍នេះបង្កប់នូវសេចក្តីប្រាថ្នារបស់ក្រុមហ៊ុន ក្នុងការរក្សាតំណែងរបស់ខ្លួនឱ្យក្លាយជាអ្នកដឹកនាំដែលឈានមុខគេ ក្នុងឧស្សាហកម្មសេវាកម្មវិជ្ជាជីវៈដោយធានាថាអាចទាក់ទាញអតិថិជន និងមានទេពកោសល្យល្អបំផុតនៅក្នុងទីផ្សារ។ នៅក្នុងការវិភាគនេះដែរ យើងនឹងបំបែកសេចក្តីថ្លែងការណ៍នៃចក្ខុវិស័យឱ្យទៅជាសមាសភាគសំខាន់ៗ ចំនួនបី ហើយយើងនឹងស្វែងយល់អំពីរបៀប ដែលធាតុនីមួយៗដើរតួនាទីយ៉ាងសំខាន់ក្នុងប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន និងភាពជោគជ័យជារួម។

**· បេសកកម្ម**

បេសកកម្មរបស់ក្រុមហ៊ុន Deloitte គឺ"ដើម្បីជួយឱ្យអាជីវកម្មរបស់អតិថិជនកាន់តែប្រសើរឡើង"។ មួយវិញទៀត Deloitte ក៏ជាស្ថាប័នប្រឹក្សាពាណិជ្ជកម្មឈានមុខគេមួយរបស់ពិភពលោក។ ហើយសេចក្តីថ្លែងការណ៍បេសកកម្មរបស់ស្ថាប័ន Deloitte គឺដើម្បីក្លាយជាស្តង់ដារនៃឧត្តមភាពដែលជាជម្រើសដំបូងរបស់អតិថិជនដែលមានទេពកោសល្យ និងងាយស្វែងរកបំផុត។

**· គុណតម្លៃ**

គុណតម្លៃរបស់ Deloitte គឺនាំមកនូវវិជ្ជាជីវៈដើម្បីបម្រើសេវាកម្មដោយភាពស្មោះត្រង់ និងថែរក្សានូវព័ត៌មានរបស់អតិថិជនបានល្អ។ តាមរយៈការធ្វើសកម្មភាពប្រកបដោយសីលធម៌ សុចរិតភាព និងធ្វើជាគម្រូនៅក្នុងសហគមន៍របស់ ក្រុមហ៊ុន Deloitte ដែលទទួលបានការជឿទុកចិត្តពីអតិថិជន និយ័តករ និងសាធារណៈជន។ ការប្រកាន់ខ្ជាប់នូវការទុកចិត្ត នោះគឺជាទំនួលខុសត្រូវដ៏សំខាន់បំផុតតែមួយរបស់យើង ហេតុផលដែលយើងធ្វើអ្វីដែលត្រឹមត្រូវជានិច្ច។

**៣.១.៣ អាស័យដ្ឋានរបស់ក្រុមហ៊ុន Deloitte**

ក្រុមហ៊ុន Deloitte មានអាស័យដ្ឋានស្ថិតនៅ អាគារវឌ្ឍនៈ ជាន់ទី៨ # ៦៦ ផ្លូវព្រះមុន្នីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

### ៣.១.៤ រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន Deloitte



## ៣.២ ដំណើរការនៃការធ្វើសវនកម្មរបស់ក្រុមហ៊ុន Deloitte មកលើធនាគារវឌ្ឍនៈ អាស៊ីចំកាត់

### ៣.២.១ ផែនការរបស់ក្រុមហ៊ុន Deloitte នៃការធ្វើសវនកម្មមកលើធនាគារវឌ្ឍនៈអាស៊ីចំកាត់

របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាហៅកាត់ថា CIFRSs។ ក្នុងនោះរួមមានដូចជា ៖

- **CIFRS ១៧** ៖ កិច្ចសន្យាធានារ៉ាប់រង (រួមទាំងវិសោធនកម្មខែមិថុនា ឆ្នាំ២០២០ និងខែធ្នូ ឆ្នាំ ២០២១ លើ IFRS ១៧)។
- **ការធ្វើវិសោធនកម្មទៅលើ CIAS ១**៖ ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ និង IFRS Practice Statement ២ ការធ្វើការវិនិច្ឆ័យសំខាន់ៗ ការបង្ហាញគោលនយោបាយគណនេយ្យ។
- **ការធ្វើវិសោធនកម្មទៅលើ CIAS ១២** ៖ពន្ធលើប្រាក់ចំណូល ពន្ធពន្យារទាក់ទងនឹងទ្រព្យសកម្ម និងបំណុលដែលកើតចេញពីប្រតិបត្តិការតែមួយ។
- **ការធ្វើវិសោធនកម្មទៅលើ CIAS ៨** ៖ គោលនយោលបាយគណនេយ្យ ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ និងកំហុសនិយមន័យនៃការប៉ាន់ស្មានគណនេយ្យ។

### ៣.២.២ ការអនុវត្តផែនការរបស់ក្រុមហ៊ុន Deloitte នៃការធ្វើសវនកម្មមកលើធនាគារវឌ្ឍនៈអាស៊ីចំកាត់

ក្នុងការអនុវត្តផែនការនៃការធ្វើសវនកម្មគឺជាដំណើរការចុះទៅធ្វើសវនកម្មផ្ទាល់ ដោយការអនុវត្តវិធីសាស្ត្រសវនកម្មទាំង៥ យ៉ាងដូចខាងក្រោម៖

១. Business Acknowledge (ការយល់ដឹងអំពីអាជីវកម្មអង្គភាព)
២. Test Of Control (វិធីសាស្ត្រក្នុងការឆែកឆេរលើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង)
៣. Test Of Transaction (វិធីសាស្ត្រឆែកឆេរទៅលើកំណត់ត្រាប្រតិបត្តិការ)
៤. Test Of Balance (វិធីសាស្ត្រឆែកឆេរទៅលើសមតុល្យនៃរបាយការណ៍ហិរញ្ញវត្ថុ)
៥. Analytical Of Procedure (វិធីសាស្ត្រវិភាគ)។

**១. កិច្ចសន្យាធានារ៉ាប់រង**

កិច្ចសន្យាធានារ៉ាប់រងមិនមានការបង្ហាញជាទិន្នន័យនៅក្នុងរបាយការណ៍សវនកម្មក្នុងឆ្នាំ២០២៣ នោះទេ។

**២. លទ្ធផលហិរញ្ញវត្ថុទទួលបានក្នុងឆ្នាំ២០២៣**

យោងតាមការធ្វើសវនកម្មពីក្រុមហ៊ុន Deloitte មកលើរបាយការណ៍ហិរញ្ញវត្ថុ របស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ស្របតាមស្តង់ដា CIAS ១ក្នុងនោះរួមមាន៖

**ប្រតិបត្តិការសាច់ប្រាក់**

- ទ្រព្យសកម្មសរុបរបស់ ABA បានកើនឡើង27% ដែលសម្រេចឈានដល់ 11.48 ពាន់លានដុល្លារ ត្រឹមដំណាច់ឆ្នាំ2023។

- សាច់ប្រាក់ងាយស្រួលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុធនាគារបានកើនឡើង 40% ក្នុងឆ្នាំ2023 ស្មើនឹងទឹកប្រាក់ ដែលបានតម្កល់ទុកជាមួយ NBC និងធនាគារផ្សេងទៀត។
- ប្រាក់ចំណេញសុទ្ធសម្រាប់ឆ្នាំ 2023 បានកើនឡើងដល់ 276.48 លានដុល្លារអាមេរិក។
- ប្រាក់បញ្ញើរបស់អតិថិជនបន្តកើនឡើងជាងឆ្នាំមុន25% ដែលសម្រេចឈានដល់ 9.03 ពាន់លានដុល្លារ។
- ផលប័ត្រប្រាក់កម្ចី ដែលផ្តល់ជូនដល់ចម្រុះវិស័យបានកើនឡើងដល់21% និងសម្រេចឈានដល់ 7.77 ពាន់លានដុល្លារនៅក្នុងឆ្នាំ 2023។
- ដើមទុនពីធនាគារជាតិកាណាដា ដែលជាភាគហ៊ុនិករបស់ ABA បានកើនឡើងពី660 លានដុល្លារក្នុងឆ្នាំចាស់ ដល់ 1.10 ពាន់លានដុល្លារបើគិតត្រឹមឆ្នាំ2023។
- សាច់ប្រាក់សុទ្ធទទួលបានពី(ប្រើប្រាស់ក្នុង)សកម្មភាពប្រតិបត្តិការមាន៧៦៧ ពាន់លានដុល្លារ។
- សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងគ្រាមាន ១.៣៣៥.១៣៤.៥៤៣ ពាន់លានដុល្លារ។

**ប្រតិបត្តិការមិនមែនសាច់ប្រាក់សំខាន់ៗ**

- ក្នុងអំឡុងឆ្នាំ២០២៣ មានការបំប្លែងប្រាក់ចំណេញរក្សាទុករបស់ធនាគារចំនួន ២៥០លានដុល្លារអាមេរិកទៅជាដើមទុន ។
- នៅឆ្នាំ២០២៤ មានការបន្តមូលបត្របំណុលសាជីវកម្មចំនួន ៣០លានដុល្លារអាមេរិក ដែលចេញដោយក្រុមហ៊ុន ខេមបូឌាអ៊ែរផតអិនវេសមិនឯ.ក សម្រាប់ការសាងសង់ និងអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិតេជោ។

**ការធ្វើការវិនិច្ឆ័យសំខាន់ៗលើលទ្ធផលហិរញ្ញវត្ថុទទួលបានពីការធ្វើសវនកម្ម**

- សកម្មភាពចម្បងក្នុងអំឡុងពេលធ្វើសវនកម្មពុំមានការផ្លាស់ប្តូរជាសារវន្តក្នុងការិយបរិច្ឆេទ។
- ទុនបម្រុង និងសំវិធានធនពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងគ្រានេះទេក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។
- ភាគលាភពុំមានការប្រកាស ឬការបែងចែកភាគលាភទេសម្រាប់ការិយបរិច្ឆេទហិរញ្ញវត្ថុនេះ។
- គិតត្រឹមការិយបរិច្ឆេទដែលរបាយការណ៍នេះក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលនឹងបណ្តាលឱ្យចំនួនសំវិធានធនទៅលើការខាតបង់របស់ឥណទានរំពឹងទុកលើទ្រព្យសកម្មហិរញ្ញវត្ថុនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះមានលក្ខណៈមិនគ្រប់គ្រាន់រហូតដល់កម្រិតជាសារវន្តនោះទេ។
- វិធីសាស្រ្តដែលយកមកប្រើប្រាស់ ដើម្បីវាយតម្លៃគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមានហេតុការណ៍ណាមួយ ហើយនឹងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្រ្ត ដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលដែរមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថានឹងមានភាពមិនត្រឹមត្រូវនោះទេ ។
- មិនមានប្រតិបត្តិការមិនប្រក្រតីណាមួយកើតឡើងក្នុងអំឡុងពេលធ្វើសវនកម្មនោះទេ។

- នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជាបានអនុម័តឱ្យធនាគារបញ្ចូលដើមទុនចំនួន ២២០ លានដុល្លារអាមេរិក ដែលធ្វើឱ្យដើមទុនសរុបកើនដល់ ១.៣២០ លានដុល្លារអាមេរិក ដែលស្មើនឹង ១.៣២០.០០០ ភាគហ៊ុនដែលមានតម្លៃចារឹក ១.០០០ដុល្លារអាមេរិកក្នុង ១ភាគហ៊ុន។

**៣. ប្រាក់ចំណេញឆ្លុះបញ្ចាំងពីការគ្រប់គ្រងដ៏ត្រឹមត្រូវ**

- ប្រាក់ចំណេញសុទ្ធសម្រាប់ឆ្នាំ2023 បានកើនឡើងដល់ 276.48 លានដុល្លារ ដែលឆ្លុះបញ្ចាំងពីប្រតិបត្តិការ។
- កំណើននេះក៏ត្រូវបានទទួលស្គាល់ថាជាសញ្ញានៃកិច្ចគ្រប់គ្រងផ្ទៃក្នុងបានត្រឹមត្រូវ។

**មូលបត្រអាចជួញដូរបាន (NCD)**

ក្នុងមូលបត្រអាចជួញដូរបានធនាគារបានដាក់មូលបត្រចំនួន ១៥៣ លានដុល្លារអាមេរិក ជាទ្រព្យធានាលើប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា(២០២៣៖១៤៣លានដុល្លារអាមេរិក ឬ ៥៨៥.១៥៥ លានរៀល) និងចំនួន ២៥ លានដុល្លារអាមេរិក (១០០.៦២៥ លានរៀល) ជាទ្រព្យធានាលើ ឥណទានវិបារូបន៍ (២០២៣៖ ២០ លានដុល្លារអាមេរិក ឬ ៨១.៧០០ លានរៀល)។

**៤. ការបង់ពន្ធលើប្រាក់ចំណូល**

ការបង់ពន្ធលើប្រាក់ចំណូលជូនរដ្ឋចំនួន ៧០.២៩លានដុល្លារ ក្នុងឆ្នាំ 2023 នៅក្នុងនោះរួមមាន៖

- បំណុលពន្ធចរន្តសមតុល្យនាចុងការិយបរិច្ឆេទមានទឹកប្រាក់ចំនួន ៤៧.២១៧.១៦៤ លានដុល្លារអាមេរិក។

**៥. ពន្ធពន្យា**

ឆ្លងតាមការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុដែលស្របទៅតាមស្តង់ដា CIAS ១២ ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ទទួលបានលទ្ធផលដូចខាងក្រោម៖

- នៅថ្ងៃទី៣១ ខែធ្នូឆ្នាំ២០២៣(បំណុល)ទ្រព្យសកម្មពន្ធពន្យារសុទ្ធមានតម្លៃ(២១.៩៨៩.៦២០) ដុល្លារអាមេរិក។
- ទ្រព្យសកម្ម និងបំណុលពន្ធពន្យារត្រូវបានកាត់កង នៅពេលមានការអនុញ្ញាតដោយច្បាប់ក្នុងការកាត់កងរវាងទ្រព្យសកម្មពន្ធបច្ចុប្បន្ន និងបំណុលពន្ធបច្ចុប្បន្នហើយនៅពេលដែលពន្ធពន្យារស្ថិតក្រោមអាជ្ញាធរពន្ធតែមួយ។

**ទ្រព្យសម្បត្តិ និងបរិក្ខារ**

- អគារជួលដែលមានតម្លៃ ៣៤.១៤៥.៦៥៥ លានដុល្លារនៅត្រឹមចុងការិយបរិច្ឆេទ និងមានតម្លៃយោង១៩.៤១២.៦៩៩លានដុល្លារ។
- គ្រឿងបរិក្ខារដែលមានតម្លៃ ១៧.៨៣០.៣០៧ លានដុល្លារនៅត្រឹមចុងការិយ និងមានតម្លៃយោង ៥.៧១៤.៧៤១លានដុល្លារ។
- កំព្យូទ័រ និងព័ត៌មានវិទ្យាដែលមានតម្លៃ ៥៧.៦៣០.៨៦២ លានដុល្លារនៅត្រឹមចុងការិយ និងមានតម្លៃយោង ៣៦.៦៣៧.៨៧៣ លានដុល្លារ។
- ការងារកំពុងសាងសង់ដែលមានតម្លៃ ៣.៤៦៩.៨១៦ លានដុល្លារនៅត្រឹមចុងការិយ និងមានតម្លៃយោង ៣.៤៦៩.៨១៦ លានដុល្លារ។

**សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម**

ធនាគារបានចុះភតិសន្យាលើការជួលទ្រព្យសកម្មរួមមានៈ អគារការិយាល័យ និងយានយន្ត។ ព័ត៌មានស្តីអំពី ភតិសន្យា ដែលធនាគារគឺជាអ្នកភតិកៈត្រូវបានបង្ហាញដូចខាងក្រោមៈ

- អគារការិយាល័យមានតម្លៃ១០១.០៤៤.៦៥៣ លានដុល្លារត្រូវបានប្រើប្រាស់សម្រាប់ ២០២៣។
- យានយន្តមានតម្លៃ ៤.៨៩៤.០៧១ លានដុល្លារត្រូវបានដាក់ប្រើប្រាស់សម្រាប់នាការិយបរិច្ឆេទ។

**ប្រាក់បញ្ញើពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ**

- នៅក្នុងឆ្នាំ ២០២៣ ក្នុងការិយដែលបានធ្វើសវនកម្មធនាគារមានគណនីចរន្តដែលមានទឹកប្រាក់ ៩៥.៩៥៥លានដុល្លារ ឬ ៣៩១.៩៨០ លានរៀល។
- គណនីសន្សំមានទឹកប្រាក់ ២៣.៤១៣.៤១៩ លានដុល្លារ ឬ ៩៥.៦៤៤ លានរៀល។
- ប្រាក់បញ្ញើមានកាលកំណត់មានទឹកប្រាក់សរុប ៨៧.០៣២.៦៥០ ឬ ៣៥៥.៥២៩ លានរៀល។
- តម្លៃសរុបប្រាក់បញ្ញើពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗនៅចុងការិយបរិច្ឆេទមានទឹកប្រាក់សរុប២០៦.៤០២.០០៩ លានដុល្លារ ឬ ៨៤៣.១៥៣លានរៀល។
- ប្រាក់បញ្ញើរបស់អតិថិជនមាន ៩.០២៦.៣០៤.៧៦៩លានដុល្លារអាមេរិក។

**ប្រាក់កម្ចី**

- ប្រាក់កម្ចីពីធនាគារដែលមានទឹកប្រាក់សរុបចំនួន១៤៦.៤១៦.៩៦៣ ឬ ៥៩៨.១១៣ ពាន់លានរៀល។ ប្រាក់កម្ចីខាងលើនេះមានចំណាយអត្រាការប្រាក់ថេរចាប់ពី ២,២០% ទៅ ៦,៨០% ក្នុងមួយឆ្នាំ។

**ទ្រព្យសកម្មអរូបិយ**

- កម្មវិធីកំព្យូទ័រដែលមានតម្លៃ២៥.៧៧៨.០៣១លានដុល្លារនៅត្រឹមចុងការិយ និងមានតម្លៃយោង ១៤.៤២៥.១១២ លានដុល្លារ។
- កម្មវិធីកំពុងសាងសង់មានតម្លៃ២.១៣០.០០០លានដុល្លារនៅត្រឹមចុងការិយ និងមានតម្លៃយោង ២.១៣០.០០០ លានដុល្លារ។

**ទ្រព្យសកម្មផ្សេងៗ**

ធនាគារបានដាក់បញ្ចូលនូវ ECL បន្ថែមមានចំនួន ៥លានដុល្លារអាមេរិក (២០.១២៥ លានរៀល) សម្រាប់ការខាតបង់នាពេលអនាគតដែលអាចកើតមានលើសេវាមេធាវី ដែលហួសកំណត់ឱនភាពនៃតម្លៃគិតត្រឹមការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៤ ។

**អនុបំណុល**

- មានអនុបំណុលសរុបទឹកប្រាក់ចំនួន ៩៦.០៥៣.៣៧២ លានដុល្លារអាមេរិកនៅក្នុងធនាគារជាតិកាណាដាក្នុងឆ្នាំ២០២៣។
- ប្រាក់ដើមដែលមានចំនួន ៩៦លានដុល្លារអាមេរិក (៣៩០.៨១៦ លានរៀល) ត្រូវសងត្រឡប់ជូនធនាគារជាតិកាណាដា ក្នុងអំឡុងការិយបរិច្ឆេទ ២០២៤ និងគ្មានការដកប្រាក់ថ្មីនៅក្នុងឆ្នាំ ២០២៣។

## ៦. ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ និងកំហុស

តាមរយៈការធ្វើសវនកម្មស្របតាមស្តង់ដា CIAS ៨ ពីក្រុមហ៊ុន Deloitte ធនាគារទទួលបាននូវលទ្ធផលដូចខាងក្រោម៖

**សំវិធានធនលើការខាតបង់ទៅតាមថ្នាក់នៃការប៉ះពាល់ទ្រព្យសកម្មនីមួយៗ**

- កិច្ចសន្យាឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុដែលមានទឹកប្រាក់សរុប៩៨.៣៧៥.០៧៨លានដុល្លារអាមេរិកគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។

**កិច្ចសន្យាឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុ**

- នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ កិច្ចសន្យាឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុមានតម្លៃសរុប ៤៦៩.០២២.៩៥០ ដុល្លារអាមេរិក។
- គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៣ ធនាគារបានកត់ត្រា ការខាតបង់ឥណទានរំពឹងទុក សម្រាប់កិច្ចសន្យាឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុចំនួន ៦៣៥.៦៩៦ ដុល្លារអាមេរិក ឬ ២.៥៩៧ លានរៀល ដែលឆ្នាំចាស់មានត្រឹមតែ ៣៥៦.២៨៩ ដុល្លារអាមេរិក ឬ ១.៤៦៧ លានរៀល។

**ចំនួនទឹកប្រាក់ដែលកើតឡើងពី ECL**

- ឥណទានផ្តល់ដល់អតិថិជនតម្លៃយោងដុលមានតម្លៃសរុបចំនួន ៧.៨៦៦.៣៤៩.៤៨៨ លានដុល្លារអាមេរិក និងសំវិធានធនលើការខាតបង់មានតម្លៃសរុបចំនួន ៩៤.០០៧.៩៧៤ លានដុល្លារអាមេរិក។
- ធនាគារបានដាក់បញ្ចូល ECL បន្ថែមរបស់ គណៈគ្រប់គ្រង ចំនួន ៥៨ លានដុល្លារអាមេរិក (២៣៣.៤៥០ លានរៀល) នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ (២០២៣៖ ១៦ លានដុល្លារអាមេរិក ឬ ៦៥.៣៦០ លានរៀល) ដោយសារតែកំណើននៃឥណទានដែលមានឱនភាពតម្លៃ និងលក្ខខណ្ឌសេដ្ឋកិច្ចមិនទាន់ច្បាស់លាស់។

**ការវិភាគគុណភាពឥណទាន**

- ទិន្នន័យខាងក្រោមនេះ បង្ហាញព័ត៌មានអំពីឥណទានទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានវាស់វែងដោយថ្លៃដើមរំលស់ ។
- ចំនួនទឹកប្រាក់ដែលមាននៅក្នុងទិន្នន័យនេះតំណាងឱ្យតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ។
- ចំពោះតម្លៃកិច្ចសន្យាសម្រាប់កិច្ចសន្យាឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុចំនួនទឹកប្រាក់នៅក្នុងទិន្នន័យនេះតំណាងឱ្យតម្លៃកិច្ចសន្យា។
- សមតុល្យជាមួយធនាគារនានាដែលមានទឹកប្រាក់សរុប ១.៤៧៧.៦៧៣.២១៣ ដុល្លារអាមេរិក និងមានសំវិធានធនលើការខាតបង់ (៨៤៨.៧៨៥) ដុល្លារអាមេរិក និងមានតម្លៃយោងទៅការិយបន្ទាប់ចំនួន ១.៤៧៦.៨២៤.៤២៨។

- ឥណទានផ្តល់ដល់អតិថិជនមានទឹកប្រាក់សរុបចំនួន ១.៤៧៧.៦៧៣.២១៣ ដុល្លារអាមេរិក និងមានសំវិធានធនលើការខាតបង់ (៩៤.០០៧.៩៧៤) ដុល្លារអាមេរិករួមទាំងតម្លៃយោងទៅការិយបន្ទាប់ចំនួន៧.៧៧២.៣៤១.៥១៤។
- មូលបត្រវិនិយោគមានទឹកប្រាក់សរុបចំនួន ៣៣៨.៤៤៥.៧៣៩ ដុល្លាអាមេរិក និងសំវិធានធនទៅលើការខាតបង់ចំនួន(៤២៩.៩៣៤)ដុល្លារអាមេរិក និងមានតម្លៃយោងទៅការិយបន្ទាប់ដែលមានចំនួនទឹកប្រាក់សរុប ៣៣៨.០១៥.៨០៥។
- ប្រាក់កក់ និងគណនីត្រូវទទួលផ្សេងៗមានទឹកប្រាក់សរុបស្មើនឹង ៤១.៨៨៤.០៥០ ដុល្លាអាមេរិក និងសំវិធានធនលើការខាតបង់ (២.៤៥១.៦៨៩) ដុល្លារអាមេរិក និងមានតម្លៃយោងទៅការិយបន្ទាប់ចំនួន ៣៩.៤៣២.៣៦១។
- កិច្ចសន្យាឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុមានជាទឹកប្រាក់សរុបចំនួន ៤៦៩.០២២.៩៥០ ដុល្លារអាមេរិក និងសំវិធានធនលើការខាតបង់ (៦៣៥.៦៩៦) ដុល្លារអាមេរិក និងមានតម្លៃយោងទៅការិយបន្ទាប់ចំនួន ៤៦៨.៣៨៧.២៥៤។
- កម្រិតសមមូលនៅក្នុងឆ្នាំ ២០២៣ សមតុល្យជាមួយធនាគារនានាដែលមានទឹកប្រាក់សរុបចំនួន ៤៨៣.៧១៧.៩៩២ ដុល្លារអាមេរិក និងសំវិធានធនលើការខាតបង់ជាទឹកប្រាក់ (៦៤៧.៥១៩) ដុល្លារអាមេរិក និងមានតម្លៃយោងទៅការិយបន្ទាប់ស្មើនឹង ៤៨៣.០៧០.៤៧៣ ដុល្លារអាមេរិក។

**ការវិភាគគុណភាពឥណទាននៅតម្លៃដករំលស់**

ទិន្នន័យខាងក្រោមនេះ បានបង្ហាញពីបម្រែបម្រួលចំនួនទឹកប្រាក់យោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងអំឡុងការិយបរិច្ឆេទដែលរួមចំណែកដល់បម្រែបម្រួលសំវិធានធនលើការខាត់បង់៖

- សមតុល្យជាមួយធនាគារនានាមានតម្លៃយោងដុលគិតជាទឹកប្រាក់សរុប ១.៤៧៧.៦៧៣.២១៣ អាមេរិក និងសំវិធានធនលើការខាតបង់ទឹកប្រាក់ចំនួន (៨៤៨.៧៨៥) ដុល្លារអាមេរិក ។
- ឥណទានផ្តល់ដល់អតិថិជនមានតម្លៃយោងដុលទឹកប្រាក់សរុប ១.៤៧៧.៦៧៣.២១៣ អាមេរិក និងសំវិធានធនលើការខាតបង់ (៩៤.០០៧.៩៧៤)ដុល្លារអាមេរិក។
- មូលបត្រវិនិយោគមានតម្លៃយោងដុលទឹកប្រាក់សរុបចំនួន ៣៣៨.៤៤៥.៧៣៩ អាមេរិក និងមានសំវិធានធនលើការខាតបង់ (៤២៩.៩៣៤) ដុល្លារអាមេរិក ។
- ប្រាក់កក់ និងគណនីត្រូវទទួលផ្សេងៗដែលមានតម្លៃយោងដុលទឹកប្រាក់សរុប ៤១.៨៨៤.០៥០ អាមេរិក និងសំវិធានធនលើការខាតបង់ចំនួន (២.៤៥១.៦៨៩) ដុល្លារអាមេរិក ។
- កិច្ចសន្យាឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុដែរមានតម្លៃយោងដុលនឹងគិតជាទឹកប្រាក់សរុបចំនួន ៤៦៩.០២២.៩៥០ អាមេរិក និងសំវិធានធនលើការខាតបង់សរុប (៦៣៥.៦៩៦) ដុល្លារអាមេរិក ។

ទិន្នន័យទាំងអស់នេះ បានរាប់បញ្ចូលទាំងការវាស់វែងឡើងវិញទៅលើ សំវិធានធនលើការខាតបង់

(បន្ទាប់ពីការផ្ទេរ) ដែលបណ្តាលមកពីការផ្លាស់ប្តូរបរិមាណ និងគុណភាពឥណទាននៃឥណទានដែលមានស្រាប់។ ទិន្នន័យនេះហើយ គឺតំណាងឱ្យការកត់ត្រឡប់នៃ ECL បន្ថែមរបស់គណៈគ្រប់គ្រងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។

## ៣.៣. ផលប្រយោជន៍ការធ្វើសវនកម្មរបស់ក្រុមហ៊ុន Deloitte ទៅលើរបាយការណ៍ហិរញ្ញវត្ថុដែលធនាគារវឌ្ឍនៈអាស៊ីចំកាត់ទទួលបាន

ការធ្វើសវនកម្មបានផ្តល់ផលប្រយោជន៍ជាច្រើនដល់ធនាគារដូចជា៖

- ធ្វើឱ្យសាធារណៈជនអាចជឿទុកចិត្តមកលើធនាគារ តាមរយៈរបាយការណ៍ហិរញ្ញវត្ថុ ដែលបានផ្សាយជាសាធារណៈក្នុងការទិញមូលបត្រ។
- កសាងទំនុកចិត្តរវាងម្ចាស់ភាគហ៊ុន និងធនាគារ។
- មានការកើនឡើងទៅលើទឹកប្រាក់វិនិយោគ ដែលបានមកពីវិនិយោគិនខាងក្រៅ បានសម្រេចចិត្តតាមរយៈរបាយការណ៍ហិរញ្ញវត្ថុ។
- ទទួលបានការកើនឡើងនៅប្រាក់ចំណូលជាប្រចាំរៀងរាល់ឆ្នាំ។
- ទទួលបានព័ត៌មានរបាយការណ៍ហិរញ្ញវត្ថុកាន់តែជាក់លាក់ស្តីអំពី ប្រាក់ចំណេញ ឬខាតបន្ទាប់ពីការធ្វើសវនកម្ម។
- កំណត់ឡើងវិញនូវភាពទន់ខ្សោយ និងខ្វះខាតនៅក្នុងប្រព័ន្ធគ្រប់គ្រងគណនេយ្យធនាគារ។
- បង្កើនកេរ្តិ៍ឈ្មោះអាជីវកម្ម ដើម្បីជាដើមទុនបន្តនៅក្នុងការធ្វើអាជីវកម្ម។
- ថ្នាក់ដឹកនាំមានទំនុកចិត្តខ្ពស់ចំពោះប្រតិបត្តិការក្នុងធនាគារ។
- បង្កើនស្ថេរភាពអាជីវកម្ម និងរីកចម្រើនជាបន្តបន្ទាប់។
- ការជឿទុកចិត្តរវាងធនាគារនិងធនាគារក្នុងការដាក់ប្រាក់បញ្ញើមកកាន់ធនាគារដែលធ្វើឱ្យធនាគារមានការកើនឡើងទៅលើទ្រព្យសកម្ម និងចំណូល។
- ទទួលបានទំនុកចិត្តពីធនាគារដូចគ្នា ធ្វើឱ្យមានភាពងាយស្រួល ក្នុងការស្វែងរកប្រភពប្រាក់កម្ចីមានលក្ខណៈជាអន្តរការី។
- ជួយស្វែងរក និងបង្ការកំហុស ការលួចបន្លំ ឬសកម្មភាពបន្លំ (fraud) ដែលអាចកើតមានក្នុងការចងក្រងរបាយការណ៍ហិរញ្ញវត្ថុក្នុងការបោះផ្សាយ។
- ធនាគារអាចទទួលបានទិន្នន័យហិរញ្ញវត្ថុ ដែលអាចប្រើសម្រាប់ការសម្រេចចិត្តយុទ្ធសាស្ត្របានល្អជាងមុន។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ជាទូទៅការធ្វើការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយមកលើធនាគារវឌ្ឍនៈអាស៊ីចំកាត់គឺជាការវិភាគដែលមានសារៈសំខាន់បំផុតក្នុងការវាយតម្លៃ វាស់វែងពីតម្លៃ ត្រួតពិនិត្យ និងសកម្មភាពរបស់សវនករដើម្បីធ្វើឱ្យក្រុមហ៊ុនទទួលបានភាពរីកចម្រើន។ បន្ទាប់ពីបានធ្វើការស្រាវជ្រាវ និងវាយតម្លៃទៅលើរបាយការណ៍ និងការអនុវត្តការងាររបស់ធនាគារកន្លងមកនេះ ក្រុមនាងខ្ញុំបានរកឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយរបស់ធនាគារដូចខាងក្រោម៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

ឆ្លងកាត់តាមការធ្វើសវនកម្មពីក្រុមហ៊ុន Deloitte ទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់នេះរួចយើងអាចសន្និដ្ឋានបានថាធនាគារពិតជាទទួលបាន៖

- ដោយមានការបញ្ជាក់ពីសវនករ ប្រាក់ចំណូលមានការកើនឡើងជារៀងរាល់ឆ្នាំ បង្ហាញពីស្ថេរភាពនៃអាជីវកម្មក្នុងការឈរជើងបន្តទៅមុខ។
- សវនករបានបញ្ជាក់ពីទិន្នន័យនៃទ្រព្យសកម្មជាបញ្ញើនៅធនាគារផ្សេងៗច្រើនជាងការិយមុនដែលបានបង្ហាញពីភាពឆ្លាតវៃក្នុងការរកចំណូលពីការប្រាក់តាមរយៈបញ្ញើរបស់ធនាគារ។
- សវនករក៏បានបញ្ជាក់អំពីប្រាក់ចំណូល ដែលបានមកពីកម្រៃជើងសារ មានកើនឡើងគួរឱ្យកត់សម្គាល់ធ្វើឱ្យយើងឃើញថា មិនត្រឹមតែប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែកេរ្តិ៍ឈ្មោះធនាគារនេះក៏ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅបណ្តាប្រទេសផ្សេងៗ ក្នុងការជ្រើសរើសយកសេវាកម្មនៃធនាគារនេះយកទៅប្រើប្រាស់។
- នៅក្នុងរបាយការណ៍សវនកកម្មក៏បានបង្ហាញថា មានការថយចុះនៅអនុបំណុល ដែលមាននៅក្នុងធនាគារជាតិកាណាដាបង្ហាញពីភាពរីកចម្រើននៃអាជីវកម្ម។
- សវនករបានបញ្ជាក់ពីការបន្ថែមដើមទុនរាល់ឆ្នាំទៅក្នុងប្រតិបត្តិការអាជីវកម្ម ដែលអាចឆ្លុះបញ្ចាំងពីភាពរឹងមាំ និងធនធានគ្រប់គ្រាន់ដើម្បីបន្តប្រតិបត្តិការអាជីវកម្មនាពេលអនាគត។
- របាយការណ៍សវនកម្មក៏បានបង្ហាញថាមូលបត្រវិនិយោគមានការកើនឡើងជាងឆ្នាំមុន ដែលអាចសបញ្ជាក់ឱ្យឃើញពីការកើនឡើងនូវទំនុកចិត្ត ដែលបានមកពី ការសម្រេចចិត្តរបស់វិនិយោគិនខាងក្រៅឱ្យមកវិនិយោគជាមួយធនាគារ ។

## ៤.២ ការវិភាគលើចំណុចខ្សោយ

បន្ទាប់ពីការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Deloitte បានបង្ហាញឱ្យឃើញថាធនាគារវឌ្ឍនៈអាស៊ីចំកាត់នៅមានចំណុចខ្វះខាតមួយចំនួនដូចជា៖

- របាយការណ៍សវនកម្មបានបង្ហាញថា ទិន្នន័យក្នុងរបាយការណ៍ហិរញ្ញវត្ថុ មូលធនរបស់ធនាគារនៅក្នុងឆ្នាំ២០២៣ និង២០២៤ មិនមានការប្រកាសបែងចែកភាគលាភទេ ដែលអាចសបញ្ជាក់ឱ្យឃើញថាមូលធន និងប្រាក់ចំណេញនៅក្នុងធនាគារមួយនេះនៅមានកម្រិត និងមិនទាន់មានការរីកចម្រើន។
- នៅក្នុងនោះរបាយការណ៍សមតុល្យដែលឆ្លងការធ្វើសវនកម្ម ក៏បានបង្ហាញឱ្យយើងបានឃើញថា បំណុលសរុបក្នុងរបាយការណ៍ហិរញ្ញវត្ថុក៏មានការកើនឡើងនៅក្នុងឆ្នាំ ២០២៤ បើប្រៀបធៀបទៅនឹងឆ្នាំ២០២៣ ។
- សវនកររកឃើញថាគណនីប្រាក់បញ្ញើរបស់ធនាគារហិរញ្ញវត្ថុផ្សេងៗ ព្រមទាំងគ្រឹះស្ថានហិរញ្ញវត្ថុ ឆ្នាំ ២០២៤ នៅក្នុងធនាគារនេះ យើងឃើញថាមានការធ្លាក់ចុះនៅមួយឆ្នាំចុងក្រោយនេះ។
- របាយការណ៍សវនកម្មបានបង្ហាញឱ្យឃើញថា ទិន្នន័យក្នុងរបាយការណ៍ហិរញ្ញវត្ថុ បង្ហាញថាមានការកើនឡើងដល់ទៅគុណនឹងពីរ ទៅលើទឹកប្រាក់នៃសំវិធានធនលើអតិថិជនសង្ស័យ នៅក្នុងឆ្នាំ ២០២៤ បើប្រៀបធៀបនឹងឆ្នាំ២០២៣។

(យោងលើទិន្នន័យក្នុងរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងឆ្នាំ ២០២៣ និង ២០២៤ របស់ធនាគារវឌ្ឍនៈ អាស៊ីចំកាត់)

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

បើយោងទៅតាមការសិក្សាស្រាវជ្រាវ និងការពិភាក្សាលម្អិតកន្លងមក ស្តីអំពីការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុ របស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ធ្វើឱ្យយើងអាចមើលឃើញថាធនាគារមួយនេះពិតជាមានប្រព័ន្ធសវនកម្មយ៉ាងរឹងមាំ ដោយបានរៀបចំធ្វើផែនការសវនកម្មជាប្រចាំឆ្នាំ ហើយការធ្វើសវនកម្មនេះផងដែរ គឺត្រូវអនុវត្តមកលើការិយាល័យកណ្តាល និងតាមគ្រប់បណ្តាសាខាទាំងអស់របស់ធនាគារនិងបានស្វែងយល់អំពីគោលបំណងនៃហានិភ័យការងារ នីតិវិធីគ្រប់គ្រងបទដ្ឋាន ទាក់ទងទៅនឹងសកម្មភាពដែលត្រូវធ្វើសវនកម្ម បង្កើតយុទ្ធសាស្ត្រ និងវិធីសាស្ត្រដែលសមស្រប ដើម្បីសម្រេចបាននូវការធ្វើសវនកម្មទទួលបានប្រសិទ្ធភាពខ្ពស់។ ការធ្វើសវនកម្មនេះ មានបំណងជួយសម្របសម្រួលជាប្រព័ន្ធសម្រាប់ការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារបានកាន់តែប្រសើរថែមទៀត។ លើសពីនេះទៅទៀត បើយោងតាមគោលការណ៍សវនកម្មបានកំណត់តួនាទី មុខងារ គោលការណ៍របស់សវនកម្មនៃធនាគារបានច្បាស់លាស់ដែលជួយជំរុញ ការអនុវត្តប្រព័ន្ធគ្រប់គ្រងឱ្យកាន់តែមានប្រសិទ្ធភាព និងជួយពង្រឹងដល់ការធ្វើការសម្រេចចិត្តបានត្រឹមត្រូវ និងកាត់បន្ថយហានិភ័យផ្សេងៗ ហើយសវនករត្រូវតែគោរពទៅតាមគោលការណ៍មួយចំនួនដែលបានកំណត់ និងទទួលខុសត្រូវទៅតាមតួនាទី ស្តង់ដាអន្តរជាតិ ក្នុងការធ្វើសវនកម្មត្រូវតែស្របទៅតាមបទដ្ឋានសវនកម្មដែលខ្លួនបានចែង ទៅតាមច្បាប់ក្រមសីលធម៌ ហើយត្រូវតែពិនិត្យរកមូលហេតុ និងបញ្ហាដែលត្រូវដោះស្រាយ ហើយព្យាយាមរកហេតុផលដើម្បីមកកាត់បន្ថយ ឬកែសម្រួលកំហុសនៅលើការងារ។ ការធ្វើសវនកម្មពីសវនករឯករាជ្យពិតជាមានសារៈសំខាន់ណាស់ នៅក្នុងការជួយសម្រួលបញ្ហាផ្សេងៗ ដល់អតិថិជន ការផ្គត់ផ្គង់ សេវាកម្មឥណទាន និងសេវាផ្សេងៗទៀត ដែលជួយជំរុញនៅក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជា និងកាត់បន្ថយហានិភ័យផ្សេងៗ។

ទន្ទឹមនឹងនេះផងដែរ បើយោងតាមការសិក្សាទៅលើប្រធានបទខាងលើ យើងអាចសន្និដ្ឋានបានថាធនាគារវឌ្ឍនៈអាស៊ីចំកាត់ ពិតជាបានរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា CIFRSs (Cambodia International Finance Reporting Standards) និងមានការអនុវត្តសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ដែលស្របទៅតាមស្តង់ដាសវនកម្មអន្តរជាតិ IIA (Institute of Internal Auditor) សម្រាប់សវនករផ្ទៃក្នុង និងស្តង់ដា សវនកម្មនិងអះអាងអន្តរជាតិនៃកម្ពុជា CIAAS (Cambodia International Auditing and Assurance Standard) សម្រាប់សវនករឯករាជ្យ។ ម្យ៉ាងវិញទៀតយើងឃើញថាធនាគារពិតជាមានការគាំទ្រ និងភាពជឿទុកចិត្តពីសំណាក់អតិថិជនទាំងនៅក្នុង និងក្រៅបណ្តាប្រទេសជាច្រើនដោយសារតែធនាគារមួយនេះមានការធ្វើសវនកម្មយ៉ាងច្បាស់លាស់មកលើរបាយការណ៍ហិរញ្ញវត្ថុ និងមានសេវាកម្មល្អ ព្រមទាំងមានការបោះផ្សាយអំពីរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចជាសាធារណៈ។

## ៥.២ ការផ្តល់អនុសាសន៍

ដោយឆ្លងកាត់តាមការធ្វើសេចក្តីសន្និដ្ឋាន និងបកស្រាយអំពីប្រធានបទខាងលើរួចមក ក្រុមនាងខ្ញុំឃើញថា ធនាគារនៅមានចំណុចខ្វះចន្លោះមួយចំនួន ដោយឃើញនូវបញ្ហាទាំងនេះ ក្រុមនាងខ្ញុំសូមផ្តល់អនុសាសន៍កែលម្អក្នុងន័យស្ថាបនា ដើម្បីស្វែងរកនៅភាពរីកចម្រើនដល់ធនាគារវឌ្ឍនៈអាស៊ីចំកាត់មួយចំនួនដូចខាងក្រោម៖

- របាយការណ៍សវនកម្មបានបង្ហាញថា ទិន្នន័យក្នុងរបាយការណ៍ហិរញ្ញវត្ថុ មូលធនរបស់ធនាគារនៅក្នុងឆ្នាំ២០២៣ និង២០២៤ មិនមានការប្រកាសបែងចែកភាគលាភទេ ដែលអាចសបញ្ជាក់ឱ្យឃើញថាមូលធន និងប្រាក់ចំណេញនៅក្នុងធនាគារមួយនេះនៅមានកម្រិត និងមិនទាន់មានការរីកចម្រើន ដូច្នេះ ធនាគារគួរតែស្វែងរកនូវវិធីសាស្រ្ត ឬយុទ្ធសាស្រ្តថ្មីៗ ដែលអាចបង្កើនប្រាក់ចំណូល ដើម្បីឱ្យម្ចាស់មូលធនទទួលបានភាគលាភក្នុងមួយឆ្នាំៗ។
- នៅក្នុងនោះរបាយការណ៍សមតុល្យដែលឆ្លងការធ្វើសវនកម្ម ក៏បង្ហាញឱ្យយើងឃើញថាបំណុលសរុបក្នុងរបាយការណ៍ហិរញ្ញវត្ថុក៏មានការកើនឡើងនៅក្នុងឆ្នាំ២០២៤ បើប្រៀបធៀបទៅនឹងឆ្នាំ២០២៣ ដូច្នេះ ធនាគារគួរមានចំណាត់ការច្បាស់លាស់ក្នុងការសងលើបំណុលសរុប ដោយកំណត់ពេលវេលា និងចំនួនទឹកប្រាក់សងត្រឡប់វិញ ដើម្បីជៀសវាងកើតមានហានិភ័យធ្ងន់ធ្ងរដោយសារបំណុល និងបាត់ភាពជឿជាក់ពីសាធារណជន។
- សវនកររកឃើញថា គណនីប្រាក់បញ្ញើរបស់ធនាគារហិរញ្ញវត្ថុផ្សេងៗ និងគ្រឹះស្ថានហិរញ្ញវត្ថុឆ្នាំ២០២៤ នៅក្នុងធនាគារនេះ យើងឃើញថាមានការធ្លាក់ចុះនៅមួយឆ្នាំចុងក្រោយនេះ ធនាគារគួរបង្កើនលើអត្រាការប្រាក់ ឬពង្រឹងលើយុទ្ធសាស្រ្តបន្ថែមទៀត ដើម្បីទាក់ទាញនូវប្រភពប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ និងគ្រឹះស្ថានហិរញ្ញវត្ថុមកកាន់ធនាគារខ្លួន ព្រោះប្រភពនៃប្រាក់ទាំងនេះជាលំហូរនៃប្រភពឥណទានដែលផ្តល់បន្តឱ្យអតិថិជន។
- របាយការណ៍សវនកម្មបានបង្ហាញឱ្យឃើញថា ទិន្នន័យក្នុងរបាយការណ៍ហិរញ្ញវត្ថុបង្ហាញថាមានការកើនឡើងដល់ទៅគុណនឹងពីរទៅលើទឹកប្រាក់នៃសំវិធានធនលើអតិថិជនសង្ស័យ ក្នុងឆ្នាំ២០២៤ បើប្រៀបធៀបនឹងឆ្នាំ២០២៣ ធនាគារគួរមានវិធានការ ឬ ដំណោះស្រាយបន្ថែមទៅលើអតិថិជនផុតកាលកំណត់សង ដើម្បីទទួលបានសាច់ប្រាក់ចូលធនាគារវិញ តាមការកំណត់ និងទទួលបានប្រាក់ចំណេញក្នុងការិយច្បាស់លាស់។

# ឯកសារយោង

# ឯកសារយោង


1. គេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា https://www.nbc.gov.kh
2. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (២៣/កុម្ភៈ/២០២៤). *ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា* ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ មាត្រា១, មាត្រា២ និងមាត្រា១៤
3. វិទ្យាស្ថានវ៉ាន់ដា. (០៨/កម្ភៈ/២០២៤). *សៀវភៅសវនកម្ម.* ទំព័រទី៣៧. ចំណុច៥.១
4. ចាន់ ស្រីនិច, ងឹម ឆេងអ៊ីន, ផល សុភាព, ម៉ិញ ចាន់ណា. (បោះពុម្ភឆ្នាំ២០២២). *ការធ្វើសវនកម្មផ្ទៃក្នុងរបស់ក្រុមហ៊ុន កូការកូឡា នៅតំបន់សេដ្ឋកិច្ចពិសេស.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់១៩. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី៥. ភ្នំពេញ. ***VIA.013.234***
5. ឈុនលី សុជាតា, ជឹម ស្រីថៃ, ម៉ែន រតី, ចេក សៅជឺ, អ៊ាន់ ស្រីអូន, អ៊ុង សារ៉ាត់. (2022). *ការធ្វើសវនកម្មផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់១៩. ជំនាញគណនេយ្យហិរញ្ញវត្ថុ. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី១១ &១២. ភ្នំពេញ. ***VIA.013.203***
6. វិទ្យាស្ថានវ៉ាន់ដា. (០៤/កុម្ភៈ/២០២៤). *សៀវភៅសវនកម្មភាគ១.* បោះពុម្ពលើកទី១០. ឆ្នាំ២០២៣ ទំព័រទី៣៧&៣៨ ចំណុច៥.១&៥.២
7. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (២៤/កុម្ភៈ/២០២៤). *ក្រមសីលធម៌សម្រាប់សវនករផ្ទៃក្នុង*
8. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (២៦/កុម្ភៈ/២០២៤). *ច្បាប់ស្តីពី សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា* ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ មាត្រា៤
9. WordPress. Khem Sarith. (2024, June 29). *និយមន័យរបាយការណ៍ហិរញ្ញ*. Retrieved February, 2 2025 from https://khemsarith.wordpress.com/2016/10/05/
10. WordPress. Khem Sarith. (2016, October 05). *និយមន័យធនាគារ.* Retrieved February, 5 2025 from https: //khemsarith.wordpress.com/2016/10/05/និយមន័យធនាគារ/
11. WordPress. Khem Sarith. (2016, October 04). *ប្រភេទខុសៗគ្នានៃធនាគា.* Retrieved February, 5 2025 from https://khemsarith.wordpress.com/2016/10/04/
12. LinkedIn. Lavneet Bansal. (2017, November 17). *A Brief History of Audit.* Retrieved February, 5 2025 from https://www.linkedin.com/pulse/brief-history-auditing-lavneet-bansal

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ



ABA
BANK
NATIONAL BANK
OF CANADA GROUP
២០២៣
របាយការណ៍
ប្រចាំឆ្នាំ




ABA
BANK
NATIONAL BANK
OF CANADA GROUP
របាយការណ៍
ប្រចាំឆ្នាំ
២០២៤



វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE
ភាគ១
សវនកម្ម
Auditing
Scanned with CamScanner
បោះពុម្ពលើកទី១១(២០២៤)
សម្រាប់ប្រើប្រាស់ផ្ទៃក្នុង




វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE
ភាគ១
ធនាគារជាតិនៃកម្ពុជា
រូបិយវត្ថុ និងធនាគារ
MONEY AND BANKING

## ១៩. បំណុលផ្សេងៗ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ពាន់ដុល្លារអាមេរិក | លានរៀល | ពាន់ដុល្លារអាមេរិក | លានរៀល |
| ចំណាយបង្គរ | ៣៩.៥៣៩ | ១៥៩.១៤៤ | ៣៨.៥៥១ | ១៥៧.៤៨១ |
| មូលប្បទានប័ត្រទូទាត់ទៅក្រៅត្រូវបង់ | ៣១.០០១ | ១២៤.៧៧៩ | ២៣.៥៧២ | ៩៦.២៩០ |
| ការផ្ទេរប្រាក់កំពុងដំណើរការ | ១៤.៦២៤ | ៥៨.៨៦២ | ១៤.៤៤១ | ៥៨.៩៩៣ |
| បំណុលផ្សេងៗ | ៨.៤២៨ | ៣៣.៩២៣ | ៨.០៦៨ | ៣២.៩៥៧ |
| ប្រាក់ចំណូលមិនទាន់ទទួលស្គាល់ | ៤.៤៣៣ | ១៧.៨៤៣ | ៤.៤៣៣ | ១៨.១០៨ |
| ពន្ធផ្សេងៗត្រូវទូទាត់ | ២.៨៨៤ | ១១.៦០៨ | ១.៥០៣ | ៦.១៣៨ |
| សំវិធានធនសម្រាប់ខ្ទង់ក្រៅតុល្យការ | ៧៦២ | ៣.០៦៧ | ៦៣៦ | ២.៥៩៧ |
| | **១០១.៦៧១** | **៤០៩.២២៦** | **៩១.២០៤** | **៣៧២.៥៦៤** |

### (ខ) សំវិធានធនលើការខាតបង់

តារាងខាងក្រោមនេះ សង្ខេបការខាតបង់រំពឹងទុកនាចុងការិយបរិច្ឆេទទៅតាមថ្នាក់នៃការប៉ះពាល់ទ្រព្យសកម្មនីមួយៗ។

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ពាន់ដុល្លារអាមេរិក | លានរៀល | ពាន់ដុល្លារអាមេរិក | លានរៀល |
| ថ្នាក់នៃសំវិធានធនលើការខាតបង់៖ | | | | |
| សមតុល្យនៅធនាគារនានា | ៩៩៧ | ៤.០១៣ | ៨៤៩ | ៣.៤៦៧ |
| ឥណទានផ្តល់ដល់អតិថិជន | ១៩២.២៧៧ | ៧៧៣.៩១៥ | ៩៤.០០៨ | ៣៨៤.០២៤ |
| មូលបត្រវិនិយោគ | ៣៨៧ | ១.៥៥៧ | ៤៣០ | ១.៧៥៦ |
| ប្រាក់កក់និង គណនីត្រូវទទួលផ្សេងៗ | ៨.៤០៦ | ៣៣.៨៣៤ | ២.៤៥២ | ១០.០១៥ |
| កិច្ចសន្យាឥណទាន និង កិច្ចសន្យាធានាហិរញ្ញវត្ថុ | ៧៦២ | ៣.០៦៧ | ៦៣៦ | ២.៥៩៧ |
| | **២០២.៨២៩** | **៨១៦.៣៨៦** | **៩៨.៣៧៥** | **៤០១.៨៥៩** |

